BMI0036

# សម្ភាសន៍ជាមួយឈ្មោះ អួន នឹម ភេទស្រី អាយុ៥៣ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ នារីពេទ្យ១៧មេសា

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិត្រមែង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិកណ្ដាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ហ៊ិន សុផានី

០១:៣១:៣៩

៣៣ទំព័រ

ផានី : ថ្ងៃនឹងទី១៦ ខែតុលា ឆ្នាំ២០១០ ។ ពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ពួកខ្ញុំមកនេះគ្រាន់ចង់ឲ្យមីងជួយរៀបរាប់ប្រវត្តិរបស់មីង ដូចថាមីងឆ្លងកាត់យ៉ាងម៉េចខ្លះបានមកដល់តំបន់ម៉ាឡៃនេះ តើមីងបានឃើញហេតុការណ៍អីខ្លះ ហើយបានជួបការលំបាកម៉េចខ្លះ ដែលមីងបានឆ្លងកាត់ តើម៉ាឡៃដឹបូងជាតំបន់អី ។ ហើយរឿងរ៉ាវទាំងអស់នេះ ពួកខ្ញុំសុំអនុញ្ញាតិយកធ្វើជាសៀវភៅ និងសម្រាប់ក្មេងៗ ស្រាវជ្រាវផ្សេងយកមកសិក្សា ឲ្យក្មេងក្រោយៗបានដឹង ។ តើមីងអនុញ្ញាតិឲ្យខ្ញុំយកទៅប្រើប្រាស់អីចឹងបានទេ?

នឹម : បាន ។

ផានី : ខ្ញុំសុំថតជារូប ក៏ដូចជាថតជាវីដេអូ ក៏ដូចជាថតជារូបថតបានទេ?

នឹម : មានជី ថតទៅ ។

ផានី : មីងឈ្មោះអីគេ?

នឹម : អួន នឹម ។

ផានី : មីងមានឈ្មោះហៅក្រៅទេ?

នឹម : អត់ ។

ផានី : មីងអាយុប៉ុន្មាន?

នឹម : អាយុប៉ុន្មាន ៥៣ ។

ផានី : មីងស្រុកកំណើតនៅណាដែរ?

នឹម : ស្រុកកំណើតនៅស្រុកភូមិត្រមែង ឃុំក្រាំងស្បូវ ស្រុកឈូក ខេត្តកំពត នឹងស្រុកកំណើត ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ធានី ៖ រាល់ថ្ងៃមីងរស់នៅកន្លែងណា?

នីម ៖ នៅស្រុកម៉ាឡៃ ភូមិកណ្ដាលរាល់ថ្ងៃ។

ធានី ៖ នៅភូមិឃុំស្រុកខេត្ត?

នីម ៖ ភូមិកណ្ដាល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យសព្វថ្ងៃ។

ធានី ៖ ឪពុកមីងឈ្មោះអីគេ?

នីម ៖ ឪមិនដឹងឈ្មោះអី អួន ឡឿ។

ធានី ៖ គាត់នៅរស់ទេ?

នីម ៖ អត់ទេ ស្លាប់អស់ហើយ។

ធានី ៖ គាត់ស្លាប់ពេលណាដែរ?

នីម ៖ ស្លាប់តាំងពី ២០០០។

ធានី ៖ ២០០០?

នីម ៖ អត់ដល់២០០០ ខ្វះម៉ាឆ្នាំទៀតបាន២០០០។

ធានី ៖ ៩៩?

នីម ៖ ចា៎!

ធានី ៖ ដោយសារអី?

នីម ៖ ឈឺ។

ធានី ៖ ចុះម្ដាយ?

នីម ៖ ម្ដាយគាត់ស្លាប់។

ធានី ៖ គាត់ឈ្មោះអីគេ?

នីម ៖ ម្ដាយឈ្មោះ ទូត ស្រីម៉ុច។

ធានី ៖ គាត់ស្លាប់ឆ្នាំណា?

នីម ៖ អានឹងស្លាប់ឆ្នាំ២០០២។

ធានី ៖ ដោយសារជម្ងឺដែរ?

នីម ៖ ចា៎! ដោយសារជម្ងឺ។

ធានី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

នីម ៖ បងប្អូនមិនដឹងប៉ុន្មាននាក់ សព្វថ្ងៃមើលរស់ៗ។

ធានី ៖ សរុបទាំងអស់ បងប្អូនប៉ុន្មាននាក់?

នីម ៖ បងប្អូនទាំងអស់៨នាក់ មើលស្រី៤ ប្រុស៤ ឥឡូវស្លាប់អស់ហើយនៅ៣នាក់។

ធានី ៖ នៅសល់ប៉ុន្មាន?

នីម ៖ នៅ៣ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

នីម ៖ ស្រី២ ប្រុស១ នៅសល់៤ ។

ធានី ៖ ស្រី២ ប្រុស២?

នីម ៖ ហ្នឹងហើយ ស្រី២ ប្រុស២ ។

ធានី ៖ អ្នកផ្សេងគាត់ស្លាប់ដោយសារអីគេ?

នីម ៖ ស្លាប់ ដឹងអីរត់បែកគ្នា មិនដឹងស្លាប់ដោយសារអី ស្លាប់ឈឺអាមកជាមួយខ្ញុំឈឺតាមផ្លូវគ្រុនចាញ់ ធំវាប់រត់មកតាមផ្លូវជាមួយគ្នា ។

ធានី ៖ រត់មកជាមួយមីងប៉ុន្មាននាក់ឈឺស្លាប់?

នីម ៖ មកជាប់ខ្ញុំតែមួយ ក្រៅពីនឹងបែកម៉ែឪ ។

ធានី ៖ ឈ្មោះអីគេ?

នីម ៖ ឈ្មោះ អួន នឿន ។

ធានី ៖ ស្រី ប្រុស?

នីម ៖ ស្រី ស្លាប់ហើយ ។

ធានី ៖ ស្លាប់ដោយសារគ្រុនចាញ់?

នីម ៖ ចា៎!

ធានី ៖ ឆ្នាំប៉ុន្មាន?

នីម ៖ ៧៩ រត់មកតាមផ្លូវ ។

ធានី ៖ មីងរៀនថ្នាក់ទីប៉ុន្មានដែរ?

នីម ៖ ខ្ញុំរៀនថ្នាក់ទី៩ពីសង្គម ។

ធានី ៖ មីងរៀនបានច្រើន?

នីម ៖ រៀនឡើងម៉ែឪខំ... ។

ធានី ៖ មីងអាចជួយរៀបរាប់បានទេ ម៉េចបានមីងមកដល់ស្រុកម៉ាឡៃ ពេលមីងមកដល់ម៉េច ចង់ឲ្យមីងរៀបរាប់ពីដំបូងមកហេតុអីមីងម៉ាឡៃ?

នីម ៖ រត់មកអត់ដឹងថ្ងៃដឹងខែទេ ព្រោះមិនគិតគូចាំអី ថ្ងៃរត់ដឹងរត់តាំងពីថ្ងៃទីប៉ុន្មានខែប៉ុន្មាន ។

ធានី ៖ ដំបូង មូលហេតុអីបានមីងរត់មកដល់ម៉ាឡៃ?

នីម ៖ រត់មកតាមពួកទ័ព។ ។

ធានី ៖ តាមអ្នកណាគេ?

នីម ៖ តាមទ័ពយើង គេហៅទ័ពខ្មែរក្រហម មកជាមួយគេជាមួយឯងមិនស្គាល់គេអីមួយ គេមកៗនឹងគេ ។ ចេះមកៗដល់នឹងៗនៅនឹងលាន់ នៅនឹងគេបោះជំរំប្រក់កៅស៊ូ កាប់ឬស្សីធ្វើគ្រែដេកនៅជន្ទ្រែរគ្នា អ្នកឈឺគ្រុនចាញ់អត់សារ៉ូដាក់អីយើងដាក់រួចៗ ចុះយើងអត់មានបាយហូបណា យើងហូបខ្វះខាត ពេលមកដល់ដំបូងមានទាន់មានអីណា ។ ដល់ពេលហើយយើងដាក់ចោល បើថាយើងសម្រាកនៅកន្លែងនឹងកាលនឹងយកគ្នាអត់រួចទេ កប់កន្លែងនឹង យើងថយមកដេកកន្លែងនេះ ។

ធានី ៖ ម៉េចអីចឹង?

នីម ៖ ចុះលើកគ្នាមិនរួច យើងក៏ឈឺដែរ គេក៏ឈឺដែរ ឈឺទាំងអស់គ្នា យើងលើកគ្នាមិនរួចកប់អីចឹងទៅ យើងដើររួចនាំគ្នារកកន្លែងដេកផ្សេងទៀត បោះជំរំរស់ផ្សេងទៀតអានឹងទុកនឹងកប់ទុកនឹងទៅ ។ ចុះបើយើងឈឺទាំងអស់គ្នា អាណាមើលអាណា អ្នកណាយកអ្នកណា ។ ៧៩ឈឺច្រើនដែរ យើងគ្មានពេទ្យអីណាតាម ។

ធានី ៖ ពីមុនដំបូងមកមូលហេតុអីបានមីងដល់ម៉ាឡៃ?

នីម ៖ ដំបូងមកយើងរត់ចេញពីភ្នំពេញ ។

ធានី ៖ កន្លែងណា?

នីម ៖ ពេទ្យ១៧មេសា ។

ធានី ៖ ពេទ្យ១៧មេសានៅខាងណា?

នីម ៖ ខាងណានៅភ្នំពេញនៅជិតៗដូចខាងលិចផ្ទះលន់ នល់ ខ្ញុំនៅតូចៗដែរ មិនចាំអាណាលិចកើតផង ។ ប៉ុនចាំពេទ្យ១៧មេសា ។

ធានី ៖ មីងដែលធ្លាប់អញ្ជើញទៅភ្នំពេញទេឥឡូវ?

នីម ៖ អត់ដែលទៅ ដែលទៅក៏មិនដែលបានដើរទៅចូលទៅហួសមកហួស ។

ធានី ៖ ពេទ្យនឹងនៅ?

នីម ៖ នៅម្តុំទឹកខ្មៅនេះ ។

ធានី ៖ ពេទ្យនៅខាងណា?

នីម ៖ ពេទ្យនៅខាងកើត អត់ចាំទេមកនឹង ព្រោះមកនឹងពេលខ្លីដូចថាយើងមិននៅកន្លែងចល័ត ដល់ពេលគេចេះឲ្យមកៗបែកម៉ែឪមកៗដល់នឹងៗ គេចូលឲ្យនៅធ្វើពេទ្យនៅនឹងៗមិនដឹងណាណៃឆ្នេងស្តាំអីទេ មិនដឹងអីសោះ ។ តាំងពីនឹងមក ចេះនៅពេទ្យនឹងរហូតមកដល់នឹង ។

ធានី ៖ កាលនឹងមីងនៅពេទ្យឆ្នាំប៉ុន្មាន?

នីម :	កាលនៅពេទ្យនឹងឆ្នាំ៧៨ ។

ធានី :	អាយុប៉ុន្មាន?

នីម :	ដូចកាលនឹងខ្ញុំអាយុ១៧ ១៨ ហើយ១៥ទេ មិនដឹង ចុះមនុស្សកាលនឹងមិនដឹងណាណែចេះ ទៅនឹងគេមកនឹងគេ ។

ធានី :	មីងនៅធ្វើពេទ្យបានប៉ុន្មានឆ្នាំ?

នីម :	នៅពេទ្យនឹងមិនបានម៉ាឆ្នាំផង គេយកមកដាក់មិនទាន់ចេះកាន់សារ៉ាំងផង ទៅឃើញគេឲ្យជួយសម្រាលកូន ខ្ញុំខ្លាចរត់ចោល គេប្រជុំឲ្យយើងខំប្រឹងជួយមើលគ្នា ។ ជួយមើលអីបើខ្លាចរត់ចោលគេទៅ២នាក់ដូចប្អូនឯង គេនៅមានស្មារតីគេនៅមើលនៅធ្វើ ឯងខ្លាចរត់ទៅ សានថាបើមិនជួយមើលគ្នាម៉េចកើត អត់មានបងៗនៅទាល់យើងនៅមើល ។ តាមទៅហៅ ទម្រាំចេះបងៗគេគ្រងបានចេះច្រើនដែរនឹង គេខំបណ្ដុះយើងច្រើន ។ ដល់ពេលនេះមកពីនឹងមករត់មកមិនដឹងថ្ងៃប៉ុន្មាន រត់មកដល់រហូតដល់រាល់ថ្ងៃ ។

ធានី :	ម៉េចបានមីងទៅនៅពេទ្យនឹងវិញ?

នីម :	កាលនឹងគេឲ្យខ្ញុំទៅ ដូចចេញពីកងចល័តមកៗនឹង ។

ធានី :	កងចល័តនៅណា?

នីម :	កងចល័តកាលនឹងខ្ញុំនៅកោះស្លា កំពត កន្លែងទំនប់កោះស្លា ។

ធានី :	មីងធ្វើទំនប់កោះស្លានឹង?

នីម :	ធ្វើ ទៅធ្វើ ។

ធានី :	មីងធ្វើប្រធាន?

នីម :	អត់ទេ កូនចៅគេ ។

ធានី :	កូនចៅម៉េច?

នីម :	នៅក្រុមគេ កងគេ គេហៅទៅៗនឹងគេ ។

ធានី :	មីងធ្វើមេកង?

នីម :	មិនដែល មិនដឹងមេកងម៉េច មេកងគេធំៗគេចាស់ៗ យើងតូចៗធ្វើមេកងម៉េច ។

ធានី :	មីងធ្វើកងចល័តនៅកោះស្លា?

នីម :	ចា៎!

ធានី :	ក្រោយមកទៀត?

នីម :	ក្រោយមកទៀតបានយកមកពេទ្យ១៧មេសាៗ បានរត់ថាឃ្លួនចូលៗរត់ៗមកនឹងរហូតមកបែកម៉ែបែកឪ ។

ធានី :	កាលនៅកងចល័តនឹង អ្នកណាគេប្រធាន?

នឹម :	ប្រធានអ្នកនៅក្នុងភូមិជាមួយគ្នា ក្រុមៗ ។

ធានី :	ស្គាល់ឈ្មោះគាត់?

នឹម :	ស្គាល់ សែអី ។

ធានី :	សែ គាត់ជាអ្នកណា?

នឹម :	សែ មិនដឹងតាគេឈ្មោះអី នៅភូមិត្រមែងដែរ ។

ធានី :	គាត់ជាអ្នកណា?

នឹម :	នឹង ខ្ញុំដឹងថាមេក្រុមខ្ញុំ កងដឹងណាណៃភ្លេចអស់ ។

ធានី :	ចុះមីងធ្វើកងចល័តនឹងមួយទេ?

នឹម :	ខ្ញុំធ្វើតែនឹង ហើយនឹងមកពេទ្យនឹងៗ ហើយមកនឹងមក ។

ធានី :	អ្នកណាចាត់តាំងឲ្យមីងមកពេទ្យ១៧នឹង?

នឹម :	អត់ស្គាល់នៅក្នុងមេក្រុម នៅភូមិក្រាំងរំដេងឈ្មោះ យាយអង់ៗ ។

ធានី :	យាយអង់នឹងអ្នកចាត់តាំងឲ្យមីងមកនឹង?

នឹម :	ចា៎!

ធានី :	គេមានប្រាប់ថាម៉េចមកធ្វើពេទ្យ?

នឹម :	ថាជ្រើសយកមកធ្វើពេទ្យ មកជួយចាក់ថ្នាំចាក់អីគេ ។

ធានី :	មីងចង់ធ្វើដែរ?

នឹម :	ចង់ដែរពុធ្វើពេទ្យខ្ជិលចង់រែកចង់ចេះចង់ដឹងដែរ ។

ធានី :	ស្ម័គ្រចិត្តមក?

នឹម :	ចា៎! ស្ម័គ្រចិត្តមកៗធ្វើស្គាល់តាជួន ជឿន ។

ធានី :	តាជួន ជឿនអ្នកណាគេ?

នឹម :	តាជួន ជឿននៅពេទ្យពីសង្គមនោះ នៅរាល់ថ្ងៃ ថានៅប៉ៃលិន ។

ធានី :	គាត់ធ្វើអីគេងារគាត់?

នឹម :	គាត់វះកាត់គ្រប់បែបយ៉ាងជួយសង្គ្រោះមនុស្សពេញទីម៉ាថ្ងៃៗម៉ាយប់ៗ គាត់វះកាត់ទល់ៗភ្លឺ គ្មានបានសម្រាកបានអង្គុយទេ សង្គ្រោះមនុស្សរាប់ម៉ឺនរាប់សែននាក់ ខ្ញុំមិនដែលឃើញទេ ។

ធានី :	គាត់ម្នាក់ឯង?

នឹម :	ហ្នឹងហើយ គាត់ចេះជាងគេតាំងពីជាប់សង្គមស្តេច ពុបងៗនិយាយ ខ្ញុំថា *"ចុះអ៊ីម្នាក់ទឹងក៏គាត់ចេះម៉ាំម៉េះ"* ឆ្ងល់នោះ គាត់ថា *"គាត់ជាប់វេជ្ជបណ្ឌិតតាំងពីសង្គមម៉េះ តាំងពីគាត់រៀននៅ*

បារាំង» យើងមិនដឹងនោះបងៗនិយាយប្រាប់ តែនេះអត់ដឹងទេ។ កាលនឹងពេលគាត់រត់មកជាមួយគាត់ដែរ ដល់ពេលយើងមកនឹង គាត់បង្រៀនយើងទៀត បង្រៀនឲ្យចេះចាក់ថ្នាំ ឲ្យចេះមើលគ្នា ឲ្យជួយសម្រាលជួយអីម៉ាចប់ ឲ្យជួយសង្គ្រោះពេលសម្រាល ណាពិបាក ណាធ្លាក់ឈាមច្រើនម៉េចៗ គាត់ឈរមើលម៉ាយប់ៗទល់ៗភ្លឺ។ ចុះមិនសូវមានពេទ្យណា យើងមកមានពេទ្យណា យើងមក៧៩ អត់មានទេ។ ដល់ពេលអីចឹង គាត់ជួយឡើងអស់រលីង គាត់ម៉ាយប់ៗគ្មានបានសម្រាកទេ អាណិតគាត់ចាស់ហើយ មុខឡើងជ្រួញមែនទែន រត់មក។ មកដល់ដំបូងយើងរៀងយ៉ាប់តិច ក្នុងព្រៃផង គ្មានផ្ទះនៅផង គ្រូនបាញ់គ្នាឯងវាច្រើន ដល់ពេលយើងរូតរាស់ធ្វើផ្លូវ ធ្វើផ្ទះធ្វើអីបាននៅ ចុះឈើច្រើននោះ កាប់ដាក់ៗ គ្រាន់ថាព្រំដែនធម្មតាគ្មានអ្នកណាចង់មកនៅ សុទ្ធតែគ្រូនបាញ់។ ពីដើមពុម៉ែខ្ញុំនិយាយថា ស្ដេចធ្វើផ្ទះឲ្យនៅ ហើយធ្វើផ្លូវឲ្យទៀត គ្មានអ្នកណាមកនៅផង។

ធានី : នៅនឹង?

នឹម : ចា៎! មកនៅនឹង កន្លែងនឹងពីសង្គម ម៉ែខ្ញុំគាត់និយាយ។

ធានី : ម្ដាយមីងប្រាប់ថាម៉េច?

នឹម : គាត់ថា«ពីដើមកូនៗឯងមកកន្លែងព្រៃនឹង សម្ដេចឪយើងនឹងធ្វើផ្ទះយើងឲ្យនៅ ឲ្យយើងមកនៅនឹង ហើយធ្វើផ្លូវឲ្យទៀត គ្មានអ្នកណាមកនៅផងកូន មកហើយរត់ទៅវិញៗ» ខ្ញុំថា«គេម៉េចនឹងមក ម៉ែឯងមើលសុទ្ធតែព្រៃគ្មានអ្នកណានៅ បើព្រៃអីចឹង ផ្លូវវែកវាលអស់រលីងរកព្រៃមិនឃើញ»។

ធានី : គាត់និយាយថានៅម៉ាឡៃយើង ឬក៏នៅតំបន់ព្រៃផ្សេង?

នឹម : គាត់និយាយថាឲ្យតែនៅតាមព្រំដែន ហើយយើងនៅព្រំដែនគាត់មកដល់ឃើញព្រំដែន គាត់ឆ្ងល់គាត់និយាយប្រាប់។

ធានី : ម្ដាយមីងបានមកលេងមីងតាមព្រំដែន?

នឹម : ហ្នឹងហើយ មកដល់នឹង មកស្លាប់នៅនឹង។

ធានី : តែអត់ដឹងថាកន្លែងនឹងកាលពីមុនជាតំបន់អី ភូមិអី ស្រុកអី?

នឹម : យី! មានដែលដឹងស្រុកអី ស្រុកទើបនឹងដាក់ អ្នកណាដឹងស្រុកអីក្នុងព្រៃ។

ធានី : កាលមុននៅក្នុងខេត្តអីស្រុកអី អត់ដឹងទេ?

នឹម : អឺ! អត់ទាន់មានអ្នកណាចែង។

ធានី : មីងនិយាយថាជួន ជឿននឹង គាត់បង្រៀនមីងធ្វើពេទ្យ ឬក៏ម៉េច?

នឹម : នៅពេទ្យ។

ធានី : ពេទ្យ១៧មេសានឹង?

នីម : ហ្នឹងហើយ ។

ធានី : គាត់នៅធ្វើជាអីគេ?

នីម : គាដួន ជឿននឹង គាត់ធ្វើពេទ្យរហូត ។

ធានី : គាត់ងារជាអីគេ នៅក្នុងពេទ្យនឹង?

នីម : គាត់ងារជាអីដឹងថាវេជ្ជបណ្ឌិត ដើរសង្គ្រោះគេម៉ង ។

ធានី : ក្នុងពេទ្យនឹងអ្នកណាធំជាងគេ?

នីម : អត់ដឹងណាគេ ដឹងប្រធានគេឈ្មោះអីផង ។

ធានី : ដឹងថាគាដួន ជឿននឹង?

នីម : ហ្នឹង ប៉ុនគាដួន ជឿននឹង ខ្ញុំដឹងគាត់នៅនឹងធ្វើការវះកាត់នៅនឹង អត់ដឹងថាគាត់ធ្វើអីៗ ។

ធានី : អត់ដឹងទេ?

នីម : ចា៎!

ធានី : គេអត់មានដែលថាគាត់នឹងជាអ្នកណា?

នីម : ប៉ុនអត់ដែលឃើញគាត់មកប្រជុំជាមួយខ្ញុំ បើប្រជុំៗរៀនពេទ្យ ឃើញតែគាត់កាន់សៀវភៅមកបង្រៀមសិស្សឲ្យចេះពេលនឹង ។

ធានី : ម៉េចមីងដឹងថាគាត់នឹងឈ្មោះដួន ជឿន?

នីម : បើដឹងម៉េច បើបងៗនៅនឹងគាត់និយាយប្រាប់ បងៗថា *«ឈ្មោះដួន ជឿននឹងឯងចេះពីសង្គមមកពេទ្យ យើងខំប្រឹងរៀនទៅ»* ។

ធានី : រៀនពីគាត់?

នីម : ហ្នឹងហើយ គាត់បង្រៀនតែម៉ង ។

ធានី : គាត់បង្រៀនម៉េច?

នីម : គាត់បើកវគ្គតាមសិក្ខាកាមម៉ាវគ្គៗ១វគ្គ២ គាត់បើកវគ្គពេទ្យបង្រៀន រៀនខាងឆ្អប រៀនខាងវះកាត់ រៀនខាងទូទៅ គាត់រៀនទាំងអស់ ។ ដឹងកាលនឹងគាត់មកបង្រៀនខ្ញុំអីចឹង តែអត់ដឹងថាគាត់ធ្វើអី ដឹងថាគាត់គ្រូបង្រៀនពេទ្យនឹង ។

ធានី : ពេលគាត់បង្រៀនមីងបង្រៀនម៉េចខ្លះ មីងអាចប្រាប់បានទេ?

នីម : បង្រៀនពីគ្រោងឆ្អឹង ពីផ្នែកមនុស្សយើងក្បាលចែកចេញជាប៉ុន្មានប្រភេទឆ្អឹងមុខ ឆ្អឹងក្រោយតាំងពីម្រាមដៃម្រាមជើងយើងទាំងអស់ ចែកសរសៃឈាមក្រហម សរសៃឈាមបេះដូងចែកទៅណាមកណា គាត់ប្រាប់ទាំងអស់ តែយើងមិនសូវចាំៗគោលៗ ចេះមិនអស់ដូចគាត់

គាត់ហានិយាយកើត យើងអត់ៗចាំ ។ ម្យ៉ាងខ្ញុំមិនសូវរៀនដងឥឡូវ ចាស់ហើយ បើកភ្នែក

លែងរួចហើយ ។

ធានី ៖ កាលពេលមីងនៅរៀននឹង ពេលមីងអាយុប៉ុន្មាន?

នីម ៖ ខ្ញុំកាលមករៀនជាមួយគាត់មកដល់នេះក៏នៅរៀន ។

ធានី ៖ កាលពេលរៀនជាមួយគាត់នៅភ្នំពេញរៀនអាយុប៉ុន្មាន?

នីម ៖ អឺ! អាយុមិនដល់២០ផង ១៧ ។

ធានី ៖ កាលពេលមីងមកដល់ភ្នំពេញ ចូលរៀនជាមួយគាត់សិន ឬក៏ធ្វើពេទ្យហើយ?

នីម ៖ ទៅដល់ធ្វើពេទ្យបណ្ដើរ រៀនបណ្ដើរ ។ ទៅដល់ជួយបងៗនឹងជួយលាងសារាំង ជួយចំហុយ

សារាំងហើយ ដល់ម៉ោងរៀនទៅរៀនទៀត ដល់ម៉ោងធ្វើការៗ ។

ធានី ៖ គេចែកគ្នាម៉េចម៉ោងរៀនម៉ោងធ្វើការ?

នីម ៖ មានវេណៗដូចយើងមានអ្នកដាំបាយឲ្យអ្នកជម្ងឺដាំបាយទៅ ដល់វេណយើងព្យាបាលទៅព្យា

បាលទៅ ។

ធានី ៖ មានពេលដាំបាយឲ្យអ្នកជម្ងឺទៀត?

នីម ៖ មាន ។

ធានី ៖ មីងធ្វើការងារម៉េចខ្លះ ពេលព្រឹកធ្វើអី ពេលថ្ងៃធ្វើអី?

នីម ៖ មានពេទ្យគេព្យាបាលទៅព្យាបាល កន្លែងពេទ្យដាំបាយ គេដាំបាយ ទៅដល់គេបែងចែក ។

ធានី ៖ តែមីងធ្វើអីគេ?

នីម ៖ ខ្ញុំទៅដល់គេឲ្យនៅកន្លែងឆ្មបវះកាត់ខាងក្រោយ ។

ធានី ៖ កន្លែងគេធ្វើអីខ្លះ?

នីម ៖ កន្លែងនឹង បងៗធំៗគេនៅនឹង គេពិនិត្យដឹងថាអ្នកណាជុំពោះ គេត្រូវវះគេវះទៅ យកបញ្ជូន

ឲ្យគាជួន ជឿននឹង ។ ដល់ពេលណាឈឺពោះសម្រាលទុកនៅនឹង យើងមកជួយសម្រាកបងៗ

ធានី ៖ កាលនឹងមីងចេះសម្រាល?

នីម ៖ ទៅតាមគេ គេកំពុងបង្រៀន ។

ធានី ៖ រៀនម៉េចខ្លះកាលនឹងមីងរៀនបានអីខ្លះ?

នីម ៖ ខ្ញុំទៅគេបង្រៀនខ្ញុំលាងសារាំង រៀនពាក់ស្រោមដៃ បង្រៀនចំហុយសារាំងរបៀបណាស្អាត

របៀបម៉េច គេបង្រៀនអាទី១ឲ្យចេះថ្នឹកអស់រលីងហើយ ឲ្យយើងឈរមើលជួយសម្រាលគេ

ហ៊ុច ។ មុនដំបូងហុចសម្ភារៈ ហុចអីខ្លះ ពេលសម្រាលនឹង យកអីខ្លះឲ្យយើងចាំៗហើយបាន

គេឲ្យយើងធ្វើខ្លួនយើង ធ្វើនឹងគេនៅនឹងដែរ គេជួយយើង គេអមយើងៗចេះ ។ ហើយខ្ញុំវរល់តែខ្លាចរត់ជិតសាប់យំផង ហើយចង់ចេះខ្លាចទៀត ។

ធានី ៖ មីងថាគេបង្រៀនមីងឲ្យចេះលាងសារាំុងលាងអីទេ ប៉ុន្តែម៉េចបានគេឲ្យមីងទៅបង្កើតកូនវិញ?

នីម ៖ ចុះយើងមិនត្រូវចំហ៊ុយសារាំុងសម្ភារៈ ហើយមិនត្រូវចាក់ថ្នាំឲ្យអ្នកជម្ងឺ យើងចាក់អត់ចំហ៊ុយបានអី ។ ដល់ពេលនេះនឹងយើងរៀបសម្ភារៈអស់នឹងមកហើយ ប្រដាប់វាស់ឈាមមកសារាំុងមក ស្រោមដៃមក ប្រដាប់អីដណ្តប់ក្មេងៗមកដាក់ជិតដៃយើងអស់រលីង ដល់ពេលនេះគេឲ្យហ៊ុចៗឲ្យគេ បើយើងអត់ហ៊ុច អត់អីបានពីណាហ៊ុចឲ្យគេ ហើយសារាំុងគេត្រូវចាក់ហើយ យើងបានអីបូមឲ្យគេ បូមថ្នាំអីៗ គេដឹងគេប្រាប់យើងៗអត់ចេះ គេប្រាប់យើងទាំងអស់ ។ ចូលដល់ដំបូងរៀនដាក់ស្តែង មិនមែនដូចយើងរៀនឥឡូវមានវគ្គស្នើទេ រៀនដឹងរៀនដល់ស្តារដាក់ស្តែងអត់ចេះ នោះចូលទៅរៀនបណ្តើរធ្វើបណ្តើរ ។

ធានី ៖ ដល់ពេលហើយអានឹងគេអត់ទាន់ឲ្យមីងបង្កើតទេ គ្រាន់ឲ្យនៅក្បែរមើលគេមើលឯង?

នីម ៖ ហ្នឹងហើយគ្រាន់ឲ្យនៅក្បែរមើលកាន់នឹង ។

ធានី ៖ កាន់សម្ភារៈ?

នីម ៖ អឺ! ឲ្យយើងមើលសម្ភារៈនឹង ហើយឲ្យយើងមើលរៀនសម្រាលរៀនអី ។

ធានី ៖ មិនមែនគ្រូជួន ជឿននឹងមកបង្រៀនទេ?

នីម ៖ មិនមែនទេ គាត់បង្រៀនតែទ្រឹស្តីទេ តែអាយើងដាក់ស្តែងមានបងៗនៅក្នុងនឹង ។

ធានី ៖ លោកគ្រូ ជួន ជឿននឹង គាត់បង្រៀនយ៉ាងម៉េចខ្លះប្រាប់តិចមើល?

នីម ៖ គាត់បង្រៀនយើងពីការសម្រាលការអីនឹង យើងរៀនឆ្លប រៀនខាងនឹង ប៉ុនគាត់បង្រៀនខ្ញុំកាលនឹងរៀនទូទៅ ។ រៀនគ្រាន់ឆ្អឹងៗហ្នឹងហើយ រៀនកន្លែងឆ្លបនឹង រៀនកន្លែងគាត់វះកាត់គាត់ប្រាប់សង្គ្រោះអីៗទៅ ហើយយើងទៅចាប់ស្ទីកន្លែងណាយើងមិនចង់ គ្រាន់រៀនឲ្យដឹងដាក់សៀវភៅឲ្យដឹង កន្លែងណាយើងចង់ចេះយើងខំអានឹងទៅ ណាយើងមិនចង់ចេះ យើងកុំខំទៅ ។

ធានី ៖ កាលនឹងគាត់បង្រៀនមីងយល់ច្រើន ចេះច្រើន?

នីម ៖ ចេះច្រើនដែរនឹង ល្មមរត់មកតាមផ្លូវ ខ្ញុំសម្រាលបាន ។

ធានី ៖ កាលពេលនៅនោះ មីងអត់ទាន់សម្រាលបានទេ?

នីម ៖ នៅនោះសម្រាលបានមួយៗមានបងនៅជាមួយទៀត ដល់ពេលទាល់ច្រកអត់មានមនុស្សយើងរត់មក៧៩ ជួបមីងណាតាមផ្លូវយើងមិននៅជួយ យើងទៅចោលម៉េច ផាប់គេ ។

ធានី ៖ ពេលមីងរៀនប៉ុន្មានខែ បានគេឈប់បង្រៀនមីងឲ្យមីងធ្វើខ្លួនឯង?

នីម ៖ ខ្ញុំរៀនមិនទាន់បានម៉ោងឆ្នាំណារត់នឹង ។

ធានី ៖ រៀនបណ្តើរធ្វើបណ្តើរ ដូចថាពេលណារៀន ពេលណានេះ រៀនរាល់ថ្ងៃ?

នីម ៖ ពេលនេះគេឲ្យយើងទៅរៀនដូចថារៀនព្រឹក ធ្វើល្ងាចទល់ម៉ោយប់ទល់ភ្លឺ ដល់ម៉ោងចូលរៀន យើងទៅរៀនទៀត ។ ដល់ហូបបាយហើយចូលព្យាបាលទៀត ចូលមើលគេទៀតជាមួយបង ហើយ បានមានពេលចេះ បើអត់ៗចេះ បានអរគុណគេជួយបង្រៀនបានចេះថ្ងៃក្រោយ ដល់រាល់ថ្ងៃ ។

ធានី ៖ រាល់ថ្ងៃមីងធ្វើពេទ្យដែរ?

នីម ៖ រាល់ថ្ងៃខ្ញុំនៅមណ្ឌល ឥឡូវខ្ញុំសុំគេឈប់ហើយតាំងពីឈឺមក ។ ខ្ញុំសុំគេឈប់ប៉ុន្មានខែហើយ ។

ធានី ៖ កាលពេលមីងនៅពេទ្យនឹងធ្លាប់ជួយសម្រាលគេដែរ ប៉ុន្តែដល់មានបងៗគេនៅជាមួយ?

នីម ៖ ចាំ!

ធានី ៖ បងៗអ្នកណាគេខ្លះ មីងចាំឈ្មោះគាត់ទេ?

នីម ៖ អូ! មិនចាំឈ្មោះគេ ភ្លេចអស់ហើយ ខ្ញុំគ្មានចាំឈ្មោះពីណាគេបានមួយទេ ចាំឈ្មោះក្នុងភូមិឯងមួយគត់ ដែលទៅជាមួយគ្នាស្រករគ្នាចាំបានខ្លះ ។

ធានី ៖ អ្នកណាគេខ្លះ មីងជួយប្រាប់ឈ្មោះ?

នីម ៖ ចាំឈ្មោះក្លូវ ខ្លូត នៅផ្ទះអស់ហើយឥឡូវនឹង ហើយអាវ៉ាន់អីនៅនេះ នឹងចាំតែភូមិឯងស្រុកឯងមកជាមួយគ្នា ។

ធានី ៖ ហ្នឹងអ្នកភូមិមកជាមួយគ្នា?

នីម ៖ ហ្នឹងហើយ ។

ធានី ៖ ធ្វើពេទ្យជាមួយគ្នាដែរ?

នីម ៖ អឺ!ហ្នឹងហើយមកនៅនឹងគ្នាឯង វ៉ាន់អីឥឡូវនៅមណ្ឌលសុខភាពប៉ោយប៉ែតមួយ ។ ដល់អីចឹង ខ្ញុំមិនសូវចាំគេអស់ ចាំតែនឹង បងៗមិនសូវចាំគេអស់ ។

ធានី ៖ ក្រៅពីដួន ជឿនមានអ្នកណាគេបង្រៀនមីងទៀតទេ?

នីម ៖ មកនេះ មានបារាំង ។

ធានី ៖ នៅពេទ្យ១៧នោះ?

នីម ៖ នៅនោះអត់ទេ មានតែគាត់ មិនដែលមានពីណាផង ។

ធានី ៖ ក្រោយមកទៀត ម៉េចបានមីងរត់មកនេះ?

នីម ៖ ចុះយួនចូលស្រុកគេថាយួនចូលហើយនៅមិនបានទេ ចេះតែរត់ៗតាមគេតែពីតែពាស ។

ធានី ៖ រត់តាមអ្នកណាគេ?

នីម : រត់តាមពួកពូមីង១ទាំងអស់ ចេះរត់តាមគេអត់ស្គាល់គេផងនឹង ចេះមកមិនដឹងណាណែ មកដល់ស្អីគេហៅណាទេ ។

ធានី : គេហៅអីគេ?

នីម : ដឹងដល់ស្អីគេទេ កន្លែងនឹង អត់ចាំទេ រត់មកតាមផ្លូវមិនដឹងផ្លូវណាណែ បើគេឲ្យរាប់ផ្លូវរត់នឹង មិនដឹងរាប់ណាបើអត់ចាំ ដែលណាគេប្រាប់ផង ។

ធានី : មីងកាលនឹងរត់តាមអ្នកណាគេ?

នីម : មកជាមួយអ៊ំ តាជួន ជឿននឹង ។

ធានី : តាជួន ជឿននឹង មកជាមួយមីងដែរ?

នីម : មក ។

ធានី : មីងរត់មកតាមគាត់?

នីម : ចាំ! មកជាមួយគាត់អីទាំងអស់ ចុះមិនដឹងមកជាមួយអ្នកណា ខ្លះមីង១ពូ១ សុទ្ធតែកាន់កាំភ្លើង យើងអត់ស្គាល់គេផង អត់ ។

ធានី : ម៉េចទៀតមីង?

នីម : ម៉េចទៀត បើអត់ចាំកន្លែងណាទៀតទេ ។

ធានី : ពេលមីងរត់ពីភ្នំពេញមកមីងជិះអីខ្លះ ម៉េចបានមកដល់កន្លែងនេះ ជួបហេតុការណ៍អីខ្លះ មីង ថាជួយសម្រាលកូនឲ្យអ្នកណាគេ?

នីម : ជួយប្រជាជន១រត់មកដូចតែយើងអីចឹងដែរ មិនស្គាល់ផង បើឈឺពោះហើយយើងមិនជួយ សម្រាលម៉េចបានតាមផ្លូវចេះជួយគ្នាទៅ ។

ធានី : ពេលមីងជួយពួកគាត់នឹង ប្រជាជននឹងគាត់មកពីណា មីងបានសួរគាត់អត់?

នីម : រត់មក អត់បានសួរថារត់មកពីណា គ្មានបានសួរអីចឹង១ទេ៧៩ រត់មកហើយ១ តែជួយ ហើយ ឲ្យកើតដុតខ្លួនហើយយើងត្រូវទៅទៀត១នឹងគេនឹងឯងទៅតាមគេដូចមនុស្សឆ្កួតមិនដឹង ទៅណាមកណាកន្លែង ។

ធានី : កាលពេលមីងមកដល់ដំបូងរត់ពីភ្នំពេញមកនៅនេះសិន?

នីម : ចាំ!

ធានី : រត់មុនដំបូងមីងសម្រាកបានមកដល់នេះ?

នីម : ដឹងរត់កន្លែងណា១ ។

ធានី : អត់ដឹងរត់តាមតាជួន ជឿនមករហូត?

នីម ៖ រត់តាមគេតាមឯងតែពាស តាដួន ជឿនមិនដឹងបែកទៅណាទៅណៃទៀត ទើបមកជួបនៅនឹងទៀត ។ ដឹងថាចេញពីភ្នំពេញមក ។

ធានី ៖ រត់មកតាមគាត់?

នីម ៖ ហ្នឹងហើយ រត់មកជាមួយគាត់អស់ ចុះបើពេទ្យគេថានៅមិនបានទេ យើងចេញៗ គាត់ចេញ យើងមិនដឹងអីចេះមក ។ មកដល់យើងមិនដឹងបែកគ្នាទៅណាអីទៅណៃ មិនដឹងបែកណាទេ បែកទៅឃើញទ័ពមកតាម ។

ធានី ៖ មីងទៅតាមទ័ពណាទៅ?

នីម ៖ ទ័ពខ្មែរក្រហម មិនដឹងទ័ពខាងណាៗ បើគេហៅទ័ពខ្មែរក្រហមៗ មិនដឹងទ័ពអស់នឹងទៅណាមកណា ចេះមកៗនឹងគេ មកពេញទឹកពេញដីមកដល់នឹង ។ មិនស្គាល់ទ័ពណាមួយសោះ ដល់មកដល់មកនៅនេះ បានឃើញគ្នីគ្នានៅច្រើនបានជ្រើសហៅទ័ពហៅអី បានដឹងថាអាណាធ្វើទ័ពធ្វើអាណាអី បើពីមុនមកគ្មានដឹងទេ ពេញទឹកពេញដីចេះមកទៅច្របូកច្របល់មិនដឹងកងណា មិនដឹងប្រជាជនណាវារទេះមានគោពេញតែព្រៃអត់ស្គាល់គេមួយ ខំសំឡឹងមើលក្រែងមានម៉ែឪមកដែរ អាងរត់ទៅវិញ រកអត់ឃើញ ។

ធានី ៖ ចុះមីងថាមកជាមួយប្អូននោះ?

នីម ៖ ប្អូនមួយមកស្លាប់នៅតាមផ្លូវ ។

ធានី ៖ តាមផ្លូវកន្លែងណាមីងចាំទេ?

នីម ៖ ឯគីឡូ១៣ កាលនឹងមកតាមភ្នំបារាំងធ្លាក់ ។

ធានី ៖ នៅណាភ្នំបារាំងធ្លាក់?

នីម ៖ បារាំងធ្លាក់នឹងហួសសាស្ត្រាទៅទៀត ហួសនឹងហើយមកចូលនេះៗហើយទៅនៅជិរំ ។

ធានី ៖ ហួសបារាំងធ្លាក់សាស្ត្រា មីងមកនៅនេះសិន?

នីម ៖ ចាំ!

ធានី ៖ កាលពេលមីងមកដល់ដំបូង មីងឃើញទិដ្ឋភាពនៅនឹងម៉េចដែរ?

នីម ៖ មកដល់នេះដំបូងសុទ្ធតែព្រៃគ្មានផ្ទះណា ហើយមកដល់ដំបូងកាកបាទចុះមកតាម ចុះមកមើលយើងហៅទៅមាត់អូរបើកអន្ករបើកអីហូប បានមានថ្នាំពេទ្យថ្នាំអីហើយលែងសូវឈឺហើយ មុនឈឺគ្មានអាណាមើលអាណា ។ ចុះសុទ្ធតែព្រៃវាគ្រូនចាញ់ច្រើនជាងគេ គ្មានអីជាងគ្រូនចាញ់មានឈឺរឿងងាប់សុទ្ធតែគ្រូនចាញ់ ។ យើងខ្វះខាតមុង ភួយអី គ្មានអ្នកណាស្ពាយបានទាំងអស់ ស្ពាយបានម៉ាខ្លួនៗ ។ ក្មេងៗឥឡូវគេប្រាប់ ចុះម៉េចវាល ។

ធានី ៖ ធ្លាប់មានក្មេងៗសួរដែរ?

នីម ៖ សួរ តូចៗនឹង ។

ធានី ៖ កូនមីង?

នីម ៖ អឺ! ចុះដើមឈើម៉ែឯងថា “ព្រែកទ្វែងធ្វើស្រែ ព្រៃលិចៗខ្លួន ឥឡូវម៉េចកាប់អស់ហើយ” ខ្ញុំថា “អើ! បើមិនកាប់ធ្វើស្រែចំការឲ្យឯងស៊ីបានអីស៊ី” ។

ធានី ៖ គេសួរដែរ បានមីងនិយាយប្រាប់? ព្រៃយ៉ាងម៉េច ព្រៃយើង?

នីម ៖ ព្រៃឈើធំៗ អោបមិនជុំទេ គេអារឈើបាននៅកំណាត់ នឹងជ្រាកចេញផ្នែកតូចមួយ អានឹងធ្វើហើយ ។

ធានី ៖ ព្រៃក្រាស់ខ្លាំង?

នីម ៖ ព្រៃក្រាស់ខ្មឹក ព្រៃល្មមម៉ាយើងខ្លាចសត្វខ្លា ។

ធានី ៖ មានដែរ?

នីម ៖ មាន ។

ធានី ៖ មីងធ្លាប់ឃើញទេ ពេលមីងមកដល់ដំបូង?

នីម ៖ មិនដែលឃើញទេ ប៉ុនគេថាគេជួបៗ ខ្ញុំខ្លាចជិតងាប់ ។

ធានី ៖ ជួបនឹងម៉េចទៅ?

នីម ៖ ដឹងគេថាគេជួប គេរត់ ជួបវាមិនបានខាំមិនបានស៊ីអីទេ គ្រាន់ថាឃើញវារត់មុន ។

ធានី ៖ ធ្លាប់មានសត្វនឹងខាំមនុស្សយើងអីទេ?

នីម ៖ អត់ដែលឃើញ គ្រាន់ឮថាគេជួបៗ អត់ដែលឮបានខាំអ្នកណាអត់ ដូចអត់មានឃើញ ។

ធានី ៖ ចុះធ្លាប់មានសត្វអីផ្សេងក្រៅពីសត្វនឹងវាខាំមនុស្សយើង ពេលមីងមកមានទេ?

នីម ៖ អត់ ដូចគេប្រយ័ត្នខ្លាំងដែរ ។

ធានី ៖ ប្រយ័ត្នម៉េច?

នីម ៖ ប្រយ័ត្នដូចថាកាកបាទគេចុះមកគេឲ្យថ្នាំឲ្យអីមានថ្នាំពស់ខាំ គេទុកការពារ ។

ធានី ៖ ចុះពេលមីងមកដល់ដំបូង?

នីម ៖ មកដល់ដំបូងអត់មានឃើញណាខាំអីផង ពពួកភ្លើងម៉ាយប់ទល់ៗភ្លឺ ។

ធានី ៖ ហើយនៅប៉ុន្មាននាក់ក្រុមមីង?

នីម ៖ អូ! នៅច្រើនណាស់ ៣០-៤០-៥០ ឲ្យស្គាល់គ្នានៅម្តុំ បបួលគ្នានៅកុំឲ្យខ្លាច ។

ធានី ៖ ហើយកាលនឹងម៉េចបានរត់ចូលព្រៃ?

នីម ៖ ដឹងគេថាម៉េច យួនកាប់សម្លាប់ចោលទាំងពូជៗ ហើយនាំគ្នារត់ ថាអីចឹងចេះរត់ទៅ ។

ធានី ៖ ចេះរត់តាមគេខ្លាចដែរ?

នីម :	អឺ! ខ្លាចបេះរត់ គ្មានដឹងទេ មកដល់នឹកមិនឃើញៗប្រជាជនមានរទេះគោ មានឆ្នាំងទូលគ្រប់មុខនឹង ខំថាឈរសំកុកចាំរកមើលម៉ាររទេះៗតាមផ្លូវក្រែងឃើញម៉ែ អាងទៅនឹងគេ អត់ឃើញ ។

ធានី :	រទេះនឹងគេទៅណាវិញ?

នីម :	រត់មកដល់ៗដែលខ្ញុំចាំមើលហួសមកដល់គេហៅលាច ។

ធានី :	លាចនៅពោធិ៍សាត់នឹង?

នីម :	ដឹងពោធិ៍សាត់ហើយណា គេហៅលាចៗ ដឹងណា ។

ធានី :	លាចនៅជាប់បាត់ដំបងនឹងមែន?

នីម :	ហ្នឹងលាចជាប់បាត់ដំបងនឹងដឹង គេហៅដល់លាច ។

ធានី :	មីងនៅចាំមើលគេ?

នីម :	នៅចាំមើលគេក្រែងឃើញម៉ែឪ ។

ធានី :	រទេះនឹងគេទៅណា?

នីម :	រទេះនឹងឃើញតែគេបរមិនដឹងទៅណា ។

ធានី :	គេបរទៅលើទៅក្រោម?

នីម :	គេបរមកព្រៃដែរ បរច្រើនណាស់ ហើយដើរច្របូកច្របល់គ្នាមិនដឹងណាៗ ។

ធានី :	ហើយមីងដើរតាមរទេះនឹងដែរ?

នីម :	បេះដើរទៅជាមួយគេជាមួយឯងទៅ ហើយកាលនឹងអត់បេះឈឺពីនឹងមក បេះមកឈឺនៅនឹងមកដល់នឹងបានឈឺកុំអីស្លាប់បាត់ ។

ធានី :	ហើយមីងតាមផ្លូវមានអីហូប?

នីម :	ហូបបាយ ។

ធានី :	មានបាយហូបដែរ?

នីម :	បាយ តាមផ្លូវខ្ញុំយកមក ។

ធានី :	មីងរត់តាមផ្លូវមីងយកបាយអង្ករមក?

នីម :	រត់មកបានអង្ករខ្លះ ហើយមកតាមផ្លូវអង្ករតាមភូមិនឹង គេនៅអត់មានមនុស្សនៅ ឃើញអង្ករបេះយកប្រកមកទៀតមក ចុះគេរត់បាត់អស់ដែរ ។

ធានី :	ដាក់បានប៉ុន្មានអង្ករ បានហូប?

នីម :	អឺ! បានអាទៃមួយនឹង ជួនអីដាក់ស្បោង ដាក់ទូល ដាក់ស្រាក់ក្រមាស្ពាយដូចយើងស្ពាយស្អី

ធានី :	មីងយកតែអង្ករមកអត់មានអីហូប ធ្វើម៉េចបានដាំហូប?

ទីម : ចេះតាមនឹង មានអំបិល ។

ធានី : ហើយយកតែអង្ករ អត់យកឆ្នាំងយកអីមក?

ទីម : អឺ! មានឆ្នាំង អត់ឆ្នាំងបានអីដាំហូប រស់ងាប់បាត់ហើយ មានឆ្នាំងមានអង្ករយកមកចេះមក ដល់ភូមិមួយយកភូមិមួយ ប៉ុនមិនដឹងភូមិអីៗប្រជាជននៅផង ចេញអស់ហើយ ចេញស្ងាត់ ថាឯងនៅក្រោយឆ្ងាយ អាគេមកដល់មុខចេញបាត់អស់ដែរ គ្មានអ្នកណានៅអត់ ស្ងាត់ ។

ធានី : ដល់ពេលមីងដើរទៅមុខតិច មានជួបហេតុការណ៍អីអត់ នៅដើរតាមគេ?

ទីម : ដើរតាមផ្លូវដូចមិនមានជួបអីផង ចេះមកៗ ។

ធានី : ឃើញមានមនុស្សស្លាប់មានអីអត់?

ទីម : មានតែអ្នកឈឺស្លាប់ ។

ធានី : មានច្រើន?

ទីម : អឺ! មិនដឹងច្រើនស្អីឃើញយូរៗមួយ ដូចមិនដឹងគាត់លក់ដំនេក ឈឺពីណាមកក៏មិនដឹង ។ បើគេអ្នកនេះដើរមកៗឈឺជុំគ្នានៅនឹងឈឺច្រើន បែបវាអស់ដៃអស់ជើង ។

ធានី : មីងអត់មានអត់ហូប ហូបគ្រប់រហូត?

ទីម : ហូប ដាំបាយហូបរហូត អត់មានអត់ផង ចេះបានអង្ករតាមផ្លូវយកតមករហូត កុំអីអត់ ហើយអត់មានយកអីទេ សន្សំតែអង្ករមករហូតមកដល់នឹងបានបបរ ។

ធានី : ពេលមីងមកដល់ដំបូងព្រៃសុទ្ធ?

ទីម : ព្រៃ ។

ធានី : កាលនឹងអ្នកណាគេអ្នកនាំមីងមកដល់នឹង?

ទីម : ដឹង បើមកតាមគេទាំងអស់គ្នា ដឹងណាណែបើអត់ស្គាល់គេៗអត់ស្គាល់យើង ចេះមក ខ្ញុំអត់ស្គាល់មែន ហើយភូមិឯងក៏គ្មានម្នាក់ទៀត អត់ទេរ ។ ដល់ពេលនៅយូរបានដឹងថាភូមិឯងនៅសាស្រ្តា បានដឹងនៅជុំៗគ្នារកគ្នាងាប់រៀងខ្លួន ។ ក្មួយនៅកំរៀងហើយខ្ញុំម៉េចដឹងរត់បែកៗគ្នា ជីទួតមួយនៅគីឡូ១៣ នៅកំរៀង ។ ដល់ពេលយើងនៅភូមិបានដឹង កើតជាភូមិកើតជាផ្លូវបានដឹង គេនៅនេះនៅនោះឯងមកដែរកាលនឹង ទៅមើលគ្នាឯងនៅមិនចេះតិច ។

ធានី : មីងថាកាកបាទក្រហមមកជួយនឹង កាលនឹងគេចងក្រុងជាតំបន់ម៉ាឡៃនៅ?

ទីម : នៅទើបមក មិនមានគេចងក្រុងភ្លាមទេ ។

ធានី : កាកបាទក្រហមនឹងខាងណាមីងដឹងទេ?

ទីម : ដឹងគេហៅកាកបាទក្រហមអីចឹង ។

ធានី : អត់ដឹងកាកបាទក្រហមអី?

នីម ៖ អត់ ។

ធានី ៖ ហើយគេមកជួយៗយ៉ាងម៉េច?

នីម ៖ គេមកឲ្យយើងទៅឈរកន្លែងស្ពាននឹង គេរាប់មើលមានប៉ុន្មាននាក់គេឲ្យអង្ករប៉ុននឹងស្បោង ។

ធានី ៖ ស្ពានកន្លែង?

នីម ៖ ស្ពាននឹង ផ្សារណាត់នឹង ។

ធានី ៖ កន្លែងព្រំដែននឹង?

នីម ៖ ហ្នឹងរាប់អង្ករឲ្យ រាប់ខ្ញាញ់ ត្រីខ ។

ធានី ៖ ចុះមីងថាពេលមកដល់នឹងភ្លាម អត់បានហូបបបរម៉េចនោះ?

នីម ៖ មកដល់នឹងមានអីហូបបើអស់ហើយ ចប់ភូមិចប់អីឆ្ងាយមកហើយ មិនហូបអង្ករតិចតួចនឹង បបរ មិនអត់ហ៊ានដាំបាយ បានកាកបាទមកទាន់បានអង្ករហូប ។

ធានី ៖ ចុះមីងឈឺពេលណា?

នីម ៖ ឈឺពេលបបរនឹង ។

ធានី ៖ បានអ្នកណាជួយមើលទៅ?

នីម ៖ មានណា អ្នកនៅជិតៗគ្នានឹង អត់ស្គាល់ក៏គេជួយមើលដែរ ។ ប៉ុនខ្ញុំពីនោះមក ណាល្មមៗ ដាក់ថ្នាំតែប៉ារ៉ា ខ្ញុំដាក់ថ្នាំអត់ស្គាយអីស្គាយតែអង្ករហើយនឹងថ្នាំ ។

ធានី ៖ ថ្នាំអីខ្លះទៅ?

នីម ៖ ថ្នាំប៉ារ៉ា អំពី ចេះស្គាយទៅៗកុំឲ្យវាអត់ពេក ណាដួលអាណាឈឺចុកចាប់អីយើងអត់មានថ្នាំអី អ្នកណាខ្លាំងឲ្យម៉ាលេប អ្នកណាខ្លាំងឲ្យ២លេបទៅ ចេះជួយគ្នា ។ មកដល់កន្លែងខ្ញុំឈឺគ្រុប ថ្នាំខ្ញុំនៅសល់តែ៤-៥បន្ទះម៉ាមុខៗ ។

ធានី ៖ ថ្នាំអីខ្លះ?

នីម ៖ ថ្នាំអំពី ក្លូរ៉ុំ តេត្រា ចេះយកមក ។

ធានី ៖ ហើយអីទៀតអំពី ក្លូរ៉ុំ តេត្រា អីទៀត?

នីម ៖ ប៉ារ៉ា ។

ធានី ៖ មួយទៀត?

នីម ៖ វីតាមីនបេ១២ ។

ធានី ៖ ក្លូរ៉ុំ គេសម្រាប់ធ្វើអី?

នីម ៖ ក្លូរ៉ុំចេះយកមកទៅ ។

ធានី ៖ ព្យាបាលអីគេ?

នីម : សម្រាប់ព្យាបាលពោះវៀនពោះអី ។

ធានី : ហើយអីគេមួយទៀត?

នីម : អាមុកស៊ីគ្លីន យើងផ្សះដួលរត់បុកទង្គិចអី ជើងដើររលាតចេះឲ្យហូបទៅវាឈឺចាប់ពេក ។

ធានី : ចុះអំពី?

នីម : អំពីក៏ហូបបានហើមជើង ហើមដៃ ។

ធានី : ដឹងថ្នាំម៉េចៗហើយ?

នីម : ចាំ! ដឹងៗគេប្រាប់អស់ហើយ អានេះថ្នាំនេះអ្នករបួសគេវះកាត់របួសក៏ហូបជាដែរ អានេះចេះជាដែរៗ ។ គេថាហកទៅថ្នាំមិនទៅសុំគេៗនៅក្នុងស្តុកនឹង គេចេញមកគេសុំគ្រប់គ្នា គេឲ្យគេរៀបមក គេឲ្យអ្នកណាទៅរកគេឲ្យអ្នកណាអត់ទៅឲ្យអ្នកណាអត់រកនៅនឹងថ្នាំ ។

ធានី : ស្រេចចិត្តមីងយក ឬមួយគេរៀបឲ្យ?

នីម : យើងសុំគេប៉ុន្មាន គេឲ្យប៉ុននឹង គេខ្លាចយើងធ្ងន់ដែរ ។

ធានី : មីងសុំអីខ្លះកាលនឹង?

នីម : ខ្ញុំសុំតែអំពី ប៉េនីសាលីន ខ្ញុំសុំថ្នាំណាខ្ញុំស្គាល់តិចៗនឹង ទៅរកថ្នាំអត់ស្គាល់យើងយកមកប្រើម៉េចកើត ។

ធានី : មីងខស្សាហ៍យកវាប្រើដែរតាមផ្លូវ?

នីម : ចាំ! តាមផ្លូវ បើមិនយកម៉េច បើជើងយើងរត់មកហើមបុកនេះបុកនោះ យើងដើរឈឺដូចពងខ្ទុះតាំងពីក្រោម យើងលេបៗទៅសះបាត់ទៅចេះដើរៗទៀត តគេនឹងអត់ស្គាល់គេរលីង ។

ធានី : មីងមកដល់កាកបាទក្រហមហើយធ្វើម៉េចទៀត?

នីម : មកដល់កាកបាទៗមកនឹង ចូលមក ។

ធានី : មីងថាឈឺ?

នីម : ឈឺនឹងមិនទាន់កាកបាទចូលទេ ទាល់តែខ្ញុំងើបឡើងប្រើសៗ ។

ធានី : អ្នកណាគេជួយព្យាបាល?

នីម : ចូលមកបានគេរើសពេទ្យរើសអីនឹង ពេទ្យចាស់ៗគេធ្លាប់ចេះអីនឹង គេព្យាបាលឡើងមកកាកបាទក្រហមសួរថាអ្នកចេះពេទ្យប៉ុន្មាននាក់ៗ គេចុះឈ្មោះធ្វើមក វាមានអង្ករមានស្អី មានត្រីខយកមកឲ្យអ្នកជម្ងឺ មានថ្នាំព្យាបាលគ្រុនចាញ់អីនឹងមានច្រើនណាស់ ជួយព្យាបាលច្រើនរស់ពីនឹងរហូតមកតក់ៗ មានកម្លាំងធ្វើផ្ទះធ្វើសម្បែងនៅ ។ បានមកដល់នឹងដីបួងហើយ យើងនៅរត់ចូលដីរំទៀត ។

ធានី ៖ ម៉េចអីចឹង?

នីម ៖ ចុះម៉ាសារគេរៃគ្នានឹងទៀត គេដេញនឹងទៀត មកដល់នឹង បាញ់គ្នារត់ចូលដល់ជំរំតាផ្ញុកខ្ញុំ ។

ធានី ៖ ចាំថាឆ្នាំប៉ុន្មានទេ?

នីម ៖ កាលរត់ឆ្នាំ៨៥ រត់ចូលជំរំ ។

ធានី ៖ ជំរំអី?

នីម ៖ ជំរំសាយអេច គេហៅសាយអេច ប៉ុន្តែខ្ញុំហៅជំរំតាផ្ញុក ចុះយើងជាប់ព្រំដែននឹងភ្នំតាផ្ញុក ។

ធានី ៖ ពេលមីងនៅនឹង មីងថាគេបង្រៀនបារាំង រើសមីងឲ្យធ្វើពេទ្យនឹង កាកបាទក្រហមប្តូបារាំង?

នីម ៖ បារាំង ។

ធានី ៖ បារាំងគេរើសមីងធ្វើពេទ្យនឹង គេមានបង្រៀនអីមីងទៀតអត់?

នីម ៖ គេបង្រៀនថែម ។

ធានី ៖ មីងស្គាល់ឈ្មោះបារាំងនឹង?

នីម ៖ ដុកទ័រអេនីកា ចុះបើគាត់បង្រៀនខាង ។

ធានី ៖ ដុកទ័រអេនីកា គាត់បង្រៀនមីង?

នីម ៖ ចា៎!

ធានី ៖ ហើយប៉ុន្មាននាក់ទៀតដែលគេចូលធ្វើពេទ្យជាមួយមីង?

នីម ៖ ច្រើន បែកអស់ទៅ ។

ធានី ៖ ប៉ុន្មាននាក់ទៅ?

នីម ៖ ២០-៣០ ច្រើន ទូទៅផង កន្លែងកុមារផង កន្លែងឆ្មបផង អ្នកណារាប់អស់ទេ ជិនៗនៅ បាត់ដំបងនៅខាងកាកបាទផង ។

ធានី ៖ កាលពេលមីងនៅធ្វើពេទ្យនឹង គេនៅបង្រៀនមីងធ្វើអីខ្លះ?

នីម ៖ ធ្វើឆ្មប ការសម្រាល ។

ធានី ៖ គាត់អ្នកបង្រៀនការសម្រាលនឹង?

នីម ៖ ចា៎! រៀនការសម្រាល រៀនការសម្រាលច្រាសជើងៗមកមុន ។

ធានី ៖ ជើងមកមុននឹងគេសម្រាយ៉ាងម៉េច?

នីម ៖ ជើងមកមុនគេបង្រៀនយើងឲ្យសម្រាលនឹង ពេលជើងមក គេឲ្យរំដោះម្តងមួយមកដុត គេឲ្យ យើងប្រែវអាផ្សិតឲ្យធូរហើយបានគេសម្រាលចេញមក ខ្វាចតឹង ។

ធានី ៖ ខ្វាចតឹងម៉េច?

នីម ៖ តឹងផ្សិតនឹង គេឲ្យប្រែវផ្សិតនឹងឲ្យដុតពីទ្វារមាសយើងនឹង បានគេឲ្យតតិចៗ ។

ធានី ៖ ធ្វើម៉េចយកចេញរួច បើបញ្ហោសអីចឹង?

នីម ៖ ចេញរួច ។

ធានី ៖ មិនធ្លាប់បង្កើតបញ្ហោស?

នីម ៖ កើត ។

ធានី ៖ កើតនៅណា?

នីម ៖ កើតនៅយើងនេះ ។

ធានី ៖ មានបញ្ហោសដែរ?

នីម ៖ ខ្វះអី ។

ធានី ៖ ថីបានបញ្ហោស?

នីម ៖ ខ្លះឲ្យជើងម្ខាងមកមុនមក ខ្លះមកជើងទាំងពីរ ។

ធានី ៖ ដល់ពេលមកជើងម្ខាង ធ្វើម៉េចយកជើងម្ខាងទៀតបាន?

នីម ៖ យក លូកយក ។

ធានី ៖ លូកដៃយក?

នីម ៖ លូកដៃយក ចាប់ជើងមកមួយទៀត ។

ធានី ៖ លូកដៃ លូកជើងដល់ពេលត្រឹមក្បាលធ្វើម៉េចទៅ?

នីម ៖ ដល់ក្បាល យើងយកដៃពីក្រោម យកមាត់វាកុំឲ្យទាក់ចេះ តែទាក់វាមក យកដៃទាក់ចេះ យើងកាន់ចង្ការនេះ ហើយដ្អឹបក្រោមក ។

ធានី ៖ កាន់ចង្ការកូននឹង?

នីម ៖ ហ្នឹងហើយ នៅក្នុងពោះ ។

ធានី ៖ ដ្អឹបស្របនឹង-ក?

នីម ៖ ហ្នឹងហើយ ឲ្យដ្អឹបស្របនឹងកយើងមក វាលើចេះទៅប្រុច អានឹងកូនតូច បើថាធំយ៉ាប់តិច ក្បាលធំ ។

ធានី ៖ បើក្បាលធំបង្កើតបានទេ?

នីម ៖ បង្កើតបាន ប៉ុនទម្រាំយើងរំដោះនឹងបាន សន្ធប់កូន ។

ធានី ៖ មានសន្ទប់អីចឹងទៀត?

នីម ៖ មានសន្ទប់ក្មេង ។

ធានី ៖ បើក្បាលតូច វាចេញមកវាស្រែកយំ?

នីម ៖ យំ ។

ធានី ៖ ដល់ពេល?

នីម ៖ អាធំ យើងយូរអត់យំ រៀបចំសង្គ្រោះគ្នា មានប្រដាប់បាឡុងជួយខ្យល់អុកស៊ីសែនជួយអីទៀត ។

ធានី ៖ បានទៅរួច?

នីម ៖ ទៅរួច ។

ធានី ៖ អីចឹងថប់ដង្ហើម?

នីម ៖ ថប់ដង្ហើមវា ថប់យូរវាចង់អស់ខ្យល់អុកស៊ីសែន អីចឹងសង្ងប់ ។

ធានី ៖ ដែលធ្លាប់មាននេះទេ យើងបង្កើតមកវា?

នីម ៖ អត់នៅមានតើ ។

ធានី ៖ មានច្រើនមានតិច?

នីម ៖ យូរៗមួយ ។

ធានី ៖ មានអារម្មណ៍ម៉េចដែរទៅ?

នីម ៖ មាននឹងមិនមានដូចថាមកផ្ទាល់ខ្លួនយើង ប៉ុនថាមកដល់ដៃយើងថាភ្លាមៗយើងបានពិនិត្យពីមុនមកអត់បញ្ហាទេ យើងដឹងត្រូវដាក់ការវះកាត់ត្រូវធ្វើម៉េច ។ តែបើយឺតយ៉ាវនៅតាមភូមិជួនកាលមកខ្មៅមួយកំណាត់ត្រឹមនឹង យើងជួយម៉េចបាន ។

ធានី ៖ ខ្មៅម៉េច?

នីម ៖ ដូចថាកូនចេញមកច្បើរនឹងហើយ វាអត់ចេញមកផុត ។

ធានី ៖ វាចេញត្រឹមនឹង?

នីម ៖ អឺ! ចេញត្រឹមនឹង ដឹកយកមកឲ្យយើងជួយៗម៉េចបានទាន់ វាយូរពេក ឲ្យនៅដៃផ្ទាល់ខ្លួនឯងអត់ដែរប៉ះទេ ។

ធានី ៖ កូននឹងវាកើតចេញមកពាក់កណ្ដាលខ្លួន?

នីម ៖ ចា៎!

ធានី ៖ ចេញពីក្បាលមុន ឬចេញ?

នីម ៖ ចេញជើងមកនៅថប់ត្រឹមនឹង វាយូរទម្រាំបានមកដល់យើង ។ មកដល់ធ្វើម៉េចយើងជួយសង្គ្រោះម៉េចទាន់វាអាចខូចខាត ។

ធានី ៖ ម្ដាយអត់អីទេ?

នីម ៖ ម្ដាយអត់អី តែកូន ។

ធានី ៖ មានច្រើនទេកើតអីចឹង?

នីម ៖ មានច្រើន យូរៗមួយ ។

ធានី ៖ គ្មានអត់សួរដឹង?

នីម ៖ ខ្លះណាអត់បានទៅពិនិត្យនៅមណ្ឌលសុខភាព រកគេអ្នកចេះដឹងស្ទាបមើលពិនិត្យបង្កិលរាល់ខែ រាល់អាទិត្យ ខ្លិល ។ អ្នកខ្លះកូនទៅពិនិត្យរាល់ថ្ងៃរាល់ខែ រាល់អាទិត្យនៅតែកូននឹងបញ្ច្រាសបានក៏មាន ។

ធានី ៖ បញ្ច្រានឹងមកពីអី ជាទូទៅ?

នីម ៖ ដឹងមកពីអី ដំណេកវាខំដេកតែអីចឹង ។ ខ្លះណាខ្ញុំជួបមួយនោះមិនដែលទេតាំងចេះធ្វើឆ្មបមក ចេះតិចឆ្នាំ៣០-៤០ កូនមួយនោះដឹងថាក្បាលនៅលើតាមពីតូច បង្កិលអត់ទៅ ហើយខ្ញុំឲ្យទៅសៀមរាប ឲ្យទៅគេមានម៉ាស៊ីនគេជួយបង្កិលនោះ ។ ទៅហើយអត់ឃើញបង្កិលមកដែលដល់ពេលសម្រាលខ្ញុំដេញឲ្យទៅសៀមរាបវិញ ទៅវះកាត់ ។

ធានី ៖ មីងប្រាប់គាត់ដែរ?

នីម ៖ ប្រាប់តែអីចឹងអត់នៅទុកទេ ។ ខ្ញុំមិនដឹងជួយម៉េចទេ បើយើងជួយបង្កិលជួយអី ហើយបើជួយបង្កិលមិនបានហើយ ឲ្យគេទៅបង្កិលមិនបានហើយថាកុំចង់នៅសម្រាលនេះ ថាឲ្យអាក្រក់ទៀតបានទៅ ថាឲ្យល្អមៗអត់ទៅទៀតបាន ចង់នៅនឹងឯង ។ ខ្ញុំថា“ខ្ញុំមិនមែនអាទិទេពទេ មិនមែនជួយអ្នកឯងបានទេ រូតទៅឲ្យលឿន” ។

ធានី ៖ ពេលនឹងគាត់ឈឺហើយឬនៅ?

នីម ៖ ទេ!ឈឺពោះអីនៅ ប៉ុនគ្រាន់ប្រាប់មុន ខ្លាចអត់បានទៅ ព្រោះសារមុននោះកូននឹងក៏អីចឹងដែរ ថានៅផ្ទះនៅតាមភូមិឈឺពោះឡើងយូរហើយបានទៅ ។ ឈឺពោះម៉ាយប់ម៉ាថ្ងៃបានទៅមណ្ឌលសុខភាពៗ ទៅដល់នោះឈឺពោះសម្រាលម៉េច ថា“ស្លាប់” ខ្ញុំអត់បានទៅផង ។

ធានី ៖ មីងនិយាយថាមានដួន ជឿន គាត់មកបង្រៀនមីងដល់នេះពេលណា?

នីម ៖ អត់មានបង្រៀននៅនេះទេ បង្រៀននៅកំរៀងនោះ ។

ធានី ៖ ដួន ជឿន គាត់មកបង្រៀនមីងនៅកំរៀង?

នីម ៖ ចា៎! បង្រៀននៅកំរៀង នៅនឹងកាលមុន ដែលយើងមិនទាន់រត់នឹង ។

ធានី ៖ នៅម៉ាឡៃ?

នីម ៖ ចា៎!

ធានី ៖ នៅឆ្នាំមុន៨៥?

នីម ៖ នៅឆ្នាំប៉ុន្មាននៅកាលនឹងមុនរត់ចូលជំរំ ។

ធានី ៖ ចន្លោះ៨៥ចុះក្រោម?

នីម ៖ ចា៎!

ធានី ៖ ហើយគាត់មកបង្រៀនមីងតែម្នាក់ទេ ហើយមានអ្នកផ្សេងទៀត?

នីម ៖ អត់មានអ្នកណាផ្សេងទៀត ។

ធានី ៖ មានមីងម្នាក់ឯង?

នីម ៖ ហឺ! ច្រើនណាស់ មានបងភន មានបងណាច្រើន ។

ធានី ៖ ប្រហែលប៉ុន្មាននាក់?

នីម ៖ ១០-២០នាក់នឹង ។

ធានី ៖ ដែលជួប ជឿន គាត់អ្នកមកបង្រៀននឹង?

នីម ៖ ចា៎!

ធានី ៖ មិនមែនមកពីខាងកាកបាទក្រហមរើសទេ ជួន ជឿនផ្សេង កាកបាទក្រហមផ្សេង?

នីម ៖ ចុះគាត់នៅនឹង បើមិនជួយបង្រៀន បើយើងមិនសំណូមពរគាត់ ។

ធានី ៖ មីងសំណូមពរទៅគាត់?

នីម ៖ ចា៎! បើយើងអត់ចេះ ហើយឲ្យយើងជួយធ្វើការងារបង្រៀនប្រជាជន បើយើងអត់ចេះមិនងាប់គេ ។ ដល់អីចឹងយើងជួយសំណូមពរគាត់ជួយពន្យល់ ជួយបង្រៀនអីខ្លះ អានឹងបានៗ បើថាចំពោះគាត់ចង់បង្រៀនយើងម៉ង ងាប់ហើយគ្មានអ្នកណាយកចំណេះមកដាក់ទានឲ្យយើងទេ ។

ធានី ៖ គាត់បង្រៀនម៉េចខ្លះកាលពេលមីងមកដល់ម៉ាឡៃដំបូង?

នីម ៖ គាត់បង្រៀនយើងចង់ចេះឆ្មប រៀនឆ្មបទៅ ការសម្រាលការអី ដូចខ្ញុំនិយាយបារាំងបង្រៀនអីចឹងដែរ ដូចគ្នាដែរ ។

ធានី ៖ តែគាត់បង្រៀនមុន?

នីម ៖ ចា៎!

ធានី ៖ ហើយបង្រៀនអីខ្លះ?

នីម ៖ រៀនគ្រោងឆ្អឹង នឹងបង្រៀនដែរ បើយើងមិនចេះក៏វិភាគជម្ងឺអត់ត្រូវដែរ ។

ធានី ៖ គាត់ប្រាប់អីចឹង?

នីម ៖ ចា៎! តាំងពីគ្រោងឆ្អឹង តាំងពីសួត តាំងពី...ស្អីទាំងអស់ ។

ធានី ៖ បង្រៀនយូរថ្ងៃទេ?

នីម ៖ យូរ ទូទៅតែម៉ង ។

ធានី ៖ រៀនប៉ុន្មានថ្ងៃប៉ុន្មានខែ?

នីម ៖ រៀនយូរថ្ងៃយូរខែ ប៉ុនរៀនបែងចែកម៉ោងពេលវេលាដូចឆក់កណ្ដៀត ចុះយើងការងារច្រើន ជួយមើលអ្នកជម្ងឺផងរៀនផង ដល់អីចឹងយើងចែកម៉ោងៗគ្នារៀនឲ្យបាន ។ មិនមែនវគ្គណារៀន សំណូមពរហៅគាត់ជួយបង្រៀនអរ ។

ធានី ៖ ពេលរៀនជាមួយជួន ជឿន មីងរៀននៅកន្លែងណា?

នីម ៖ បង្រៀននៅកន្លែងមន្ទីរនឹង ។

ធានី ៖ មន្ទីរពេទ្យរាល់ថ្ងៃ?

នីម ៖ ចាំ! ចេះរៀនទៅ ។

ធានី ៖ រៀននៅមន្ទីរពេទ្យនឹងរាល់ថ្ងៃ?

នីម ៖ ចាំ!

ធានី ៖ ពេលដែលមីងនៅរៀននឹង រៀននៅកន្លែងណា ផ្នែកណានៃមន្ទីរពេទ្យ?

នីម ៖ ហ្នឹងផ្ទះនឹងគេរុះអស់ហើយ អានេះផ្ទះថ្មីគ្មានផ្ទះណាទៀតខ្ទេចអស់ហើយ ។

ធានី ៖ អ្នកដែលស្នាក់នៅពេទ្យនឹង ភាគច្រើនអ្នកណាគេ? ពេលមីងរៀនជាមួយគាត់នឹង មានប្រជាជនយើងទេ ឬមួយជាកងទ័ព?

នីម ៖ រៀនកាលនឹងមានកងទ័ពដែរ មានអ្នកនៅកងទ័ព មានគេមករៀនជាមួយយកទៅព្យាបាលនៅតាមយោធាអីគេ អត់ចេះហៅនឹងគេ ។

ធានី ៖ មីងមិនមែនពេទ្យខាងកងទ័ពទេ?

នីម ៖ ទេ! ខ្ញុំនៅពេទ្យប្រជាជន ។

ធានី ៖ ក្រៅពីជួន ជឿននឹង មានអ្នកផ្សេងទៀតធ្វើពេទ្យធំនៅនឹង?

នីម ៖ គ្មានអ្នកណាចេះធំ មានតែគាត់តាំងពីសង្គមណាមក នឹងសុទ្ធតែមកថ្មីៗដូចគ្នាមិនដឹងអីដូចគ្នាសៀវភៅគាត់មិនដឹងទៅណាអស់ហើយ ។

ធានី ៖ មីងរៀនជាមួយគាត់ចេះច្រើន?

នីម ៖ រៀនចេះល្មមទប់ទល់ខ្លួនឯង ។ អត់ទេ សុំម៉ារស់ ។

ធានី ៖ មីងរកនឹកមើលប៉ុន្មានខែ គាត់ទៅវិញ ជួន ជឿន?

នីម ៖ កាលនឹងមិនដឹងប៉ុន្មានខែ គ្មានអ្នកណាចាំគិតខែ ដល់គេរត់ចូលជិរំអស់ទៀត យើងរត់ទៀតហើយអ្នកណាដឹងប៉ុន្មានខែ ។

ធានី ៖ រត់ចូលជិរំបានគាត់លែងបង្រៀនមីងទៅ?

នីម ៖ ហ្នឹងបែកគ្នាទៅណាបាត់ទៀត ។

ធានី ៖ អត់ដឹងគាត់ទៅណាទេ?

នីម ៖ អត់ ។

ធានី ៖ ដល់ក្រោយពេលនៅជំរំ មានកាកបាទក្រហមនៅបង្រៀនមីងទៀតទៅ?

នីម ៖ ចាំ!

ធានី ៖ ខាងដុកទ័រអានីកា?

នីម ៖ ហ្នឹងហើយ អេនីកា ហ្នឹងទៅជំរំ ។

ធានី ៖ បង្រៀនហើយទៅណា?

នីម ៖ ជួយបង្រៀនថែមទៀត ដល់ពេលគេរំសាយជំរំឲ្យទៅតាមស្រុកភូមិយើងវិញ ដល់ខ្ញុំមិនដឹងទៅស្រុកភូមិណាដូចមិនដឹងថាទៅរកស្រុកអត់ឃើញផង នឹកឃើញក្នុងចិត្ត បេះរកស្រុកម៉ែមិនឃើញខ្ជិលទៅ បកមើលគេមើលឯង គេនៅនេះគេងាប់ៗនឹងគេ រស់ៗនឹងគេ បេះនៅនឹងគេចុះមកនៅយូរហើយ គេអត់ឲ្យបាយស៊ីអត់យូរ ។

ធានី ៖ កាលពេលមីងទៅជំរំនឹងមីងធ្វើពេទ្យទៀត?

នីម ៖ ធ្វើពេទ្យឆ្មប ។

ធានី ៖ ពេទ្យអីគេ?

នីម ៖ ពេទ្យឆ្មប ។

ធានី ៖ ហៅមន្ទីរពេទ្យអីគេ?

នីម ៖ មន្ទីរពេទ្យសាយអេចនឹង ។

ធានី ៖ ពេទ្យឆ្មបនឹង?

នីម ៖ ចាំ!

ធានី ៖ ចុះមីងដែលជួបប្រទះគាត់គ្រុនចាញ់ គាត់មានផ្ទៃពោះត្រូវសម្រាលអីមានទេ?

នីម ៖ មាន ។

ធានី ៖ ច្រើនទេ?

នីម ៖ ហ៊ាំ! កាលនឹងច្រើនណាស់ កាលអ្នកសម្រាលកំពុងឈឺពោះក្តៅរងាញាក់ ជួសឈាមមានមេរោគៗសម្រាលផងឈឺពោះផង ។

ធានី ៖ ធ្វើម៉េចទៅ?

នីម ៖ ដាក់សារ៉ូបណ្តើរ សម្រាលហើយបេះបន្តសារ៉ូ ។

ធានី ៖ តែដាក់សារ៉ូ អត់ចាក់ថ្នាំ?

នីម ៖ ដាក់សារ៉ូលាយថ្នាំៗគ្រុនចាញ់ ដូចថាត្រូវគ្រុនប៉ាស៊ីប្រូម រីវ៉ាក់អី យើងប្រើតាមនឹង ។

ធានី ៖ មានច្រើន?

នីម : មានច្រើន រឿងជម្ងឺគ្រុនចាញ់មិនបាច់និយាយ ។

ធានី : ដល់ពេលអីចឹងអត់មានគ្រោះថ្នាក់អីដល់គាត់?

នីម : អត់ទេ គ្មានគ្រោះថ្នាក់អី ចុះមានពេទ្យច្រើនគ្មានគ្រោះថ្នាក់អី ។

ធានី : មិនមែនទេ ចង់និយាយថាគាត់មានផ្ទៃពោះផង គាត់មានគ្រុនចាញ់ផង អត់មានគ្រោះថ្នាក់ដល់កូនហើយនឹង?

នីម : បើគាត់មកភ្លាមៗអត់ទេ ច្រើនយូរៗមួយ ច្រើនគាត់ស្ដឹកនៅផ្ទះ គាត់មិនមករកយើង ដល់គាត់ខ្លាំង ឬសន្លំហើយ មានផ្ទៃពោះផង គាត់សន្លំផង ជួនកាលអត់នៅ ជួនកាលនៅ ។

ធានី : ជួនកាលគាត់អាចរស់ជីវិតដែរ?

នីម : ចា៎!

ធានី : ហើយកូននឹងទៅដែរ?

នីម : ទៅដែរ ព្រោះម៉ែទៅហើយ ។

ធានី : អត់វះ?

នីម : វះតិចខែ មិនដឹងយកទៅចិញ្ចឹមណា ។

ធានី : លែធ្លាប់មានគ្រប់ខែ ធ្លាប់មានគាត់គ្រុនចាញ់?

នីម : បើនៅជំរំសាយអេចនឹង ត្រូវវះទៅអីនឹងដឹកទៅជំរំខាវអ៊ីដាងទៀត ។

ធានី : មើលទៅមានច្រើនទេ?

នីម : មិនមានច្រើនទេ យូរៗមួយ មានអ្នកឌឺ ។

ធានី : អ្នកឌឺម៉េច?

នីម : អ្នកឌឺ មិនចេញពីផ្ទះឈឺចេះទំរន់នៅផ្ទះថាអត់អីៗ ។ អត់ដឹងដូចថាដឹងដែរ អ្នកខ្លះធ្លាប់ជួបយើងណែនាំប្រាប់រឿងមានគ្រោះថ្នាក់ពេលមានផ្ទៃពោះជាអីខ្លះ ប្រាប់ទាំងអស់គាត់មិនទៅតាមផង ។ ដល់មកដល់យើងស្គាល់មនុស្ស ហួសពេលហើយ បើគាត់នៅដំអកអីចឹង ។

ធានី : តាំងពីមីងប្រកបវិជ្ជាជីវជាឆ្មប សម្រាលបានកូនប៉ុន្មាន?

នីម : អត់ដែលរាប់ទេ ។

ធានី : ចុះអ្នកភូមិយើងម្ដុំៗនេះដែលពឹងពាក់មីងសម្រាលអីទេ?

នីម : សុទ្ធតែចៅទាំងអស់ពេញភូមិ ។ ទៅដើរមើលអ្នកយាយរហូត ដល់ធ្លាយគីឡូ៩ហៅយាយដែរ យាយៗពេញភូមិ ។

ធានី : មីងមានអារម្មណ៍ម៉េចដែរ ពេលសម្រាលឲ្យគេជាលើកដំបូង?

នីម ៈ អូ! ពេលសម្រាលដឹងតែរត់ផង យំផង ភ័យខ្លាចសព្វបែបយ៉ាង គ្រាន់តែឃើញឈាមក៏ខ្លាចដែរ ។

ធានី ៈ ចង់ពេលដែលមីងសម្រាលផ្ទាល់ដៃដំបូង មីងមានអារម្មណ៍ម៉េច?

នីម ៈ ញ៉ូវ ភ័យខ្លាចគេមានគ្រោះថ្នាក់ មានបញ្ហាអី បើឯងអត់ទាន់ស្ទាត់អីចឹង បើបងៗអត់នៅជិត អត់ហ៊ានធ្វើទេ ។ ដឹងសុខចិត្តរត់ចោលហើយ ។

ធានី ៈ អារម្មណ៍ភ័យផង ខ្លាចផង តែធ្វើ?

នីម ៈ ភ័យផង ខ្លាចផង ប៉ុនចង់ថាគេខំឲ្យយើងចេះ គេថាឲ្យយើងខ្វាំងមិនថាល្មមៗទេណា ។

ធានី ៈ តែសម្រាលបានជោគជ័យ?

នីម ៈ ចា៎! ខ្ញុំសម្រាលអត់ដែលអីរហូត គុណបុណ្យអី មិនហៅមិនរកគាំងពីចេះកាន់ពោះប្រជាជនមក មិនដែលឲ្យរបូតនៅដៃខ្ញុំមួយ កូនក៏អីចឹងដែរ ។

ធានី ៈ ពេលមីងកូន មីងសម្រាលខ្លួនឯង?

នីម ៈ អត់ទេ ខ្ញុំមិនដែលមានកូនផង កូនក្រៅខោទាំងអស់ ។

ធានី ៈ កូនក្រៅខោ?

នីម ៈ ហ្នឹងហើយ និយាយលេងអីមែនទែន ។

ធានី ៈ កូនយកមកពីណា?

នីម ៈ គេកើតចោលនោះ នៅនេះគេកើតចោលមិនចេះតិច ។

ធានី ៈ នៅភូមិយើង?

នីម ៈ គេអ្នកមករកស៊ី គេអត់យកទៅ ខ្ញុំចេះចិញ្ចឹម អាមួយទៀតខ្ញុំដាក់ផ្ទះនោះៗឥឡូវធំជាងនេះ ។

ធានី ៈ តើកូនប៉ុន្មានដែលមីងយកមកចិញ្ចឹម?

នីម ៈ អានោះសាច់ឯង ក្មួយឯង៣ ។

ធានី ៈ ត្រូវជាក្មួយ?

នីម ៈ ក្មួយបង្កើត ឪស្លាប់ទៅ ។

ធានី ៈ ហើយចុះម្ដាយគាត់ទៅណា?

នីម ៈ ម្ដាយមានប្ដីទៀត ។

ធានី ៈ គាត់ខស្សរាហ៍មកលេងជាមួយមីង?

នីម ៈ មក ។

ធានី ៈ ហើយមកមើលកូនមើលអីដែរ?

នីម ៈ ចា៎!

ធានី ៖ កូននឹងប៉ុន្មាន?

នីម ៖ កូនធំកម្ទោះ ពុថាគេជិតមានចៅ ។

ធានី ៖ កូនធំមានចៅកូនត្រូវក្មួយ?

នីម ៖ ហ្នឹងហើយ ។

ធានី ៖ គាត់ដឹងមីងត្រូវជាអី?

នីម ៖ ចឹដឹងអី ដឹងតាំងពីតូចៗខ្ញុំប្រាប់ ។

ធានី ៖ ចុះអាមួយមិញ?

នីម ៖ អាមួយមិញអត់ដឹង ។

ធានី ៖ អាមួយមិញយកធ្វើកូន?

នីម ៖ ហ្នឹងហើយកូនម៉ែង ។

ធានី ៖ អានឹងអាណិតជាងគេ?

នីម ៖ តូចជាងគេ អត់ដឹងអី ក្រៅខោទាំងអស់អត់មានមួយ ថាឈឺពោះខ្លួនឯងសម្រាលខ្លួនឯងមិនកើតទេ ឆ្អែតឆ្អន់ហើយ ហត់ហើយ សម្រាលឡើងឆ្អែត ។

ធានី ៖ ម៉េចបានអ៊ំអត់ចង់បានខ្លួនឯង?

នីម ៖ ឃើញគេពិបាក ។

ធានី ៖ សុខចិត្តជួយគេ អត់ជួយខ្លួនឯង?

នីម ៖ អត់ ជួយខ្លួនឯងអត់បាន ។

ធានី ៖ ខ្លាច?

នីម ៖ ខ្លាច អីចឹងកុំយកតែម៉ែង ។

ធានី ៖ អ៊ំចង់ធ្វើឆ្មប?

នីម ៖ អឺ! ដំបូងនៅផ្ទះអត់ចង់ទេ ដល់ពេលចេញមក គេឲ្យមកនៅកន្លែងឆ្មប កន្លែងវះកាត់ក្រោយនឹងហើយគេបង្រៀនដង យំដងៗរត់ដង ដល់មកដល់នេះបានខំចង់មែនទែន ចង់ចាប់ផ្តើមម៉ោយប់ថ្ងៃមាំមួនៗ ចាប់ផ្តើមរហូតនៅនឹងៗរហូតដល់៨៥រត់នៅជំរំតាង៊ុក បារាំងដឹកទៅមុនយកដាក់បោះតង់មុនគេ សម្រាលមួយថ្ងៃមួយយប់២០នាក់ ។

ធានី ៖ មីងម្នាក់ឯង?

នីម ៖ ម្នាក់ឯង ហើយដាក់មុនគេ កើតប្រុចដាក់ប្រុច ប្រអប់សាពុំងដាក់តុហែល បារាំងយកមក ។

ធានី ៖ ហត់?

នីម ៖ អត់បានដេករលីន បញ្ឈរភ្នែកទល់ភ្លឺ ចុះអ្នកដឹកទៅឈឺពោះច្រើន ពេលដឹកទៅពេលបាញ់គ្នាដុន១៩៩៥ ដឹកខ្ញុំទៅជាមួយអ្នកជម្ងឺ ទៅដល់គេបោះតង់ដាក់ៗ ខ្លាចទាហានខ្មៅណាស់ ខ្ញុំឃើញទាហានខ្មៅដើរចូល គេយាមអត់ដឹងអីគ្មានចេះនិយាយថៃអីនឹងគេ ឃើញគេមកសុទ្ធតែស្រីៗឈឺពោះ ខ្ញុំខ្លាចណាស់ញ័របុកពោះអស់ហើយៗ មិនសមមើលអ្នកជម្ងឺថា មកជិតខ្ញុំដែន ខ្ញុំខ្លាចគេ មានកាំភ្លើងមានអី ហើយគ្មានបាំងនៅជិត គេអាឡែនជូនអ្នកជម្ងឺមកៗ ឯងខ្លាចជិតស្លាប់ ចេះនៅធ្មេចភ្នែកនៅក្នុងបន្ទប់អត់ហ៊ានចេញទៅណាៗ

ធានី ៖ ជួយសម្រាលពួកគាត់?

នីម ៖ ជួយសម្រាលគេនឹងៗ

ធានី ៖ គ្រប់គ្នានៅនឹង?

នីម ៖ អឺ! គ្រប់គ្នាទាំងអស់ៗ

ធានី ៖ ចុះបានអ្នកណាជួយជួតកូនក្មេងនឹង?

នីម ៖ គ្មានអ្នកណាជួយជួតទេ ម្នាក់ឯង អស់មួយដល់មួយ... លើកកូនដាក់ទៅទន្ទឹមម៉ែហើយៗហត់ណាថ្ងៃចូលជំរំហត់មែនទែនៗ

ធានី ៖ បន្ទាប់មកទៀតម៉េចទៀត ក្រោយពីចេញពីជំរំមក?

នីម ៖ ចេញពីជំរំនឹងមកនៅពេទ្យនឹងៗ

ធានី ៖ គេហៅពេទ្យអី?

នីម ៖ មណ្ឌលសុខភាព ពីមុនអតីតស្រុកៗ

ធានី ៖ កាលមុនអតីតស្រុកអីគេ?

នីម ៖ នៅកន្លែងនឹងមានអតីតវាមានវះកាត់ មានអី កាលតាមជួន ជឿននៅៗ

ធានី ៖ គាត់ធ្វើកន្លែងនឹង?

នីម ៖ នឹងអតីតមានវះកាត់មានអី ដល់ពេលចូលមកវិញ យើងអត់មានទេ មានការវះកាត់ដែរ តែមានការវះកាត់តិចតួច ឥឡូវគេបំបាត់ចោលហើយ គេឲ្យមានតែមណ្ឌលស្រុកម៉ាឡៃៗ

ធានី ៖ ដល់ពេលអីចឹងមីងនៅធ្វើពេទ្យនៅនឹងទៀត?

នីម ៖ ចាំ! ពេទ្យនៅនឹងនៅកន្លែងឆ្នបទៀតៗ

ធានី ៖ រហូតដល់ពេលណា?

នីម ៖ រហូតដល់ឥឡូវនឹង ឆ្នបរហូតអត់ទៅណាទេៗ

ធានី ៖ ចុះតាជួន ជឿនគាត់មកពេល៨៥ ដុត៨៥គាត់លែងមក?

នីម ៖ ៨៥គាត់នៅកំរៀង តាំងពីចេញពីជំរំមកវិញ អត់មានទេៗ

ធានី ៖	បាត់ហូត អត់ដឹងគាត់ទៅណា?

នីម ៖	អត់ដឹង ។

ធានី ៖	ឥឡូវគាត់នៅកំរៀង?

នីម ៖	ចា៎! នៅកំរៀង នៅប៉ៃលិនទេដឹង ។

ធានី ៖	គាត់ទៅមកៗចល័ត?

នីម ៖	ចា៎! មិនដឹងនៅណាខ្លះ ចៅគាត់នៅនេះច្រើនដាង ។

ធានី ៖	ដែលឃើញគាត់មកនេះ?

នីម ៖	អត់ដែលឃើញមក ។

ធានី ៖	ចៅគាត់នៅនេះ?

នីម ៖	ចា៎! អត់ឃើញផងចៅគាត់ ។

ធានី ៖	មីងធ្លាប់បង្កើតចៅគាត់?

នីម ៖	អត់ទេ ។

ធានី ៖	នៅពេលណាមានសន្តិភាពពេញលេបនៅស្រុកយើងនេះ ដែលថាប្រជាជនមកច្រើន?

នីម ៖	ប្រជាជនមកច្រើនឆ្នាំប៉ុន្មាន ឆ្នាំយើងរៀបចំមណ្ឌលហើយ កំពុងរៀបចំចងក្រងមណ្ឌលៗ ហើយគេបែងចែកកាលមុនដាក់ខេត្តបាត់ដំបង អាខ្លះដាក់អីមិនទាន់ចែកដូចចែកត្រឹមនោះមក គឺឡូ៩មកនេះខេត្តបន្ទាយមានជ័យ ត្រង់នេះបាត់ដំបង ។

ធានី ៖	ពីមុនគេដាក់បាត់ដំបងទៅទាំងអស់?

នីម ៖	ហ្នឹងហើយ ដល់ពេលឥឡូវគេចែកមក គេរៀបៗចូលទៅរៀន ។ ខ្ញុំទៅរៀននេះនឹង ឆ្នាំ៩៨ ដែលចូលរៀននៅក្រសួង ។

ធានី ៖	៩៨ រៀននៅក្រសួងណា?

នីម ៖	ក្រសួងសុខាភិបាលខេត្តបន្ទាយមានជ័យ ។

ធានី ៖	គេហៅទៅរៀន?

នីម ៖	ហៅទៅរៀន យើងទៅរៀនបណ្តុះបណ្តាលមកធ្វើការទៀត ។

ធានី ៖	គេរៀនម៉េចខ្លះ?

នីម ៖	ការនឹងគេឲ្យទៅរៀនខាងជំនាញ ដូចថាយើងខាងឆ្មប គេឲ្យយើងទៅរៀនខាងពន្យាកំណើត គេទៅភ្នំពេញ ពន្យាកំណើត ការសម្រាលកូនតាមប៉ាតូក្រាស ព្យាបាលម៉េចៗតាមដាន ម៉េចៗ ។

ធានី ៖	គេបង្រៀនថែម?

នីម : គេបង្រៀនថែម គេហៅបណ្តុះបណ្តាលថែម ។

ធានី : មិនមែនបង្រៀនឡើងវិញ?

នីម : មិនមែនទេ គេបង្រៀនចុះៗដូចថាការងារក្នុងមណ្ឌលនឹង មុខងារឆ្មបនឹងមានអីខ្លះ ខាងចាក់ថ្នាំកូនក្មេង ខាងពន្យាកំណើត ចាក់ថ្នាំ ដាក់កង ហើយទៅរៀននឹង ការសម្រាល តាមដានអ្នកសម្រាល ពិនិត្យផ្ទៃពោះៗតាមដានម៉េច កូនគឺងពោះ ដូចឥឡូវការពារអាយុជីវិតម្តាយ ។

ធានី : គេមានចេញលិខិតអីបញ្ជាក់ថាមីងជាឆ្មបអី?

នីម : កាលគេឲ្យទៅរៀននឹង ម៉ែឈឺខ្ញុំអត់បានទៅរៀននឹងគេទេ អត់បានចេញបញ្ជាក់អីទេ គ្រាន់ថានៅកន្លែងឆ្មបនឹង ខ្ញុំអ្នកគ្រប់គ្រង ។

ធានី : នៅឆ្មបពេទ្យយើងនេះ?

នីម : គ្មានបញ្ជាក់អីទេ មានក្រដាសហ៊ុន សែន មានបញ្ជាក់មេដៃមាស ។

ធានី : អ្នកគ្រប់គ្រងពេទ្យនៅនឹងអ្នកណាគេ?

នីម : ប្រធានមណ្ឌលឡើងថ្មី ។

ធានី : ពីមុន?

នីម : ពីមុនមកនៅតិចៗដឹងណាខ្លះ អ្នកស្រី យើងហៅមីងកេងឈ្មោះក្រៅ ឈ្មោះក្នុងមិនចាំឈ្មោះគាត់ អឺ! ឃឹម ស៊ីម៉ន អ្នកគ្រប់គ្រងកន្លែងនឹង ។ តែឥឡូវគាត់គ្រប់គ្រង៣មណ្ឌល មណ្ឌលម៉ាឡៃមួយ ប៉ោយប៉ែតមួយ សេរីសោភ័ណ្ឌមួយ ។

ធានី : ឥឡូវនឹង?

នីម : ឥឡូវ ។

ធានី : ចុះកាលពីមុន?

នីម : ពីមុនគាត់រហូតមកដែរ ។

ធានី : គាត់នៅតែម៉ាឡៃយើងទេ?

នីម : នៅតែម៉ាឡៃនឹង ។

ធានី : ដល់ពេលឥឡូវទាំងអស់?

នីម : ឥឡូវបណ្តុះបណ្តាលឡើងទៅប្រធានសមាជិកអូឌី៣មណ្ឌល ។

ធានី : កាលពីមុនពេដែលមីងមកដល់ម៉ាឡៃនឹង អ្នកណាគេអ្នករៀបចំចងក្រង?

នីម : ហ្នឹង ឃឹម ស៊ីម៉ននឹង ។

ធានី : អ្នកគ្រប់គ្រងទូទៅ?

នីម ៖ ទូទៅចាប់ឆាយ ពូលីមគេមកពីពេទ្យចិន គេមកពីចិន ដូចថាទៅរៀននៅចិន ហើយគេមកគេបានជួយបណ្តុះបណ្តាលពេទ្យនឹងថៃម ។ ឥឡូវគេបំបែកទៅយោធាអស់ហើយ ។

ធានី ៖ អ្នកគ្រប់គ្រងទូទៅ ពីព្រោះមីងនិយាយមិញមានយោធា មានពេទ្យធម្មតា ចុះអ្នកទូទៅ?

នីម ៖ ទូទៅ មានពូហៃៗ អត់មានគាត់គ្រប់គ្រងទេ គាត់វេជ្ជបណ្ឌិតម៉ង ហើយអ្នកគ្រប់គ្រងឥឡូវនេះប្រធានមណ្ឌលនេះ កូនយាយកេង កូនឃីម ស៊ីម៉នឈ្មោះអីអេង ជីតាវាអត់ស្គាល់ ។

ធានី ៖ ក្រៅពីពេទ្យ ចុះខាងយោធាអ្នកណាគេអ្នកគ្រប់គ្រង?

នីម ៖ ពូលីម ។

ធានី ៖ ដូចថាអ្នកណាគ្រប់គ្រងដូចយើងរាល់ថ្ងៃមានមេភូមិមេឃុំ ចុះកាលសម័យនឹងអ្នកណាគេគ្រប់គ្រង មកដំបូង?

នីម ៖ អូ! អត់ស្គាល់គេទេ ។

ធានី ៖ ចុះអ្នកណាគេអ្នកផ្តួចផ្តើមបង្កើតតំបន់ម៉ាឡៃនឹង?

នីម ៖ មិនដឹងពីណា បើមកដល់នឹងនៅនឹងទាំងអស់គ្នា តំបន់តស៊ូ ។

ធានី ៖ ចង់ដឹងថាអ្នកណាផ្តួចផ្តើមគំនិតឲ្យមានតំបន់នឹង ហើយមានគេខាងជំរំមកជួយ ហើយយើងរត់ទៅដីថៃ?

នីម ៖ ណាគេកាលមុនមានណាគេនៅមានឈឹម បូន្នី ។

ធានី ៖ ឈឹម បូន្នីនឹងគាត់ខាងអីគេ?

នីម ៖ គាត់នៅកន្លែងស្រុកនឹង ។

ធានី ៖ ក្រៅពីគាត់មានអ្នកណាផ្សេងទៀត?

នីម ៖ អត់ ឥឡូវគាត់ផ្លាស់ទៅនៅកាន់ស្រុកណាបាត់ហើយ ចុះសួរកាលនោះវាមានកាលនឹង មានឈ្មោះនឹង ជួយបណ្តុះបណ្តាល ជួយយលពូជ ដំបូងយើងកាប់ចំការធ្វើពូជ មិនឈឹម បូន្នីទៅដាក់ពាក្យជាមួយថៃយកគ្រាប់ពូជ ។ បើយើងទិញពោតគេឲ្យគេចុះទិញរបស់ប្រជាជនយើងបានៗ អានឹងបានចង់និយាយថា ឈឹម បូន្នីនឹង សួរកាលនោះ មានកាលនឹងអ្នកចាត់វែង ។

ធានី ៖ កាលនឹង៨៥ម៉េចបានរត់ចូលដីថៃ?

នីម ៖ ចុះគេបាញ់គ្នាយើងមិនខ្លាចត្រូវគ្រាប់ ៨៥ម៉ាជួរភ្នំរូងទៅមើលគ្រាប់យួនពេញ ។

ធានី ៖ កន្លែងណា?

នីម ៖ ភ្នំរូងទៅជ្រុងនោះ មើលឃើញភ្នំនោះ ។

ធានី ៖ ហួសស្រុកម៉ាឡៃទេ?

នីម :	អត់ហួសទេ ក្នុងស្រុកម៉ាឡៃ មានរូងគេនៅក្នុងនឹង ហើយឥឡូវបងៗអ៊ំគេកំទេចកន្ទាក់មីនចូលក្នុងនឹង ហើយយួនដាក់ ខ្ញុំចូលមើល ហើយដាក់សសរប៉ុនៗនេះ ដាក់ដង្កែវគ្នា អ្នកណាបាញ់វាងាប់ទេ គេថាយួនៗ ឯងមិនដែលឃើញមុខយួនម៉េចផង នៅតែកន្លែងព្យាបាល ។

ធានី :	រូងនឹងនៅដល់រាល់ថ្ងៃ?

នីម :	នៅ រាល់ថ្ងៃអាហ៊ានចូលខ្លាចពស់ ។

ធានី :	មានពស់?

នីម :	ហ៎! ណាដឹងបើមិនដែលមានអ្នកណាចូលពីមុន គេនៅគេដុតទៀនចូល....ចូលដល់ជណ្ដើរក្រោម ។ ខ្ញុំចូលម្ដងឃើញអាចម៌ពស់ឡើងមួយគំនរខ្ញុំរត់ ខ្ញុំខ្លាច ។ គ្រាប់នៅនឹងច្រើនណាស់ គេកំទេចចោល គ្មានអ្នកណាយកចេញខ្លាចគ្រាប់ល្អផ្ទុះ ។

ធានី :	ខ្ទុចអស់អត់?

នីម :	អ្នកណាដឹង ។

ធានី :	មីងឈប់ធ្វើពេទ្យហើយ?

នីម :	ខ្ញុំឈប់ប៉ុន្មានខែ ។

ធានី :	ម៉េចបានឈប់?

នីម :	ឈឺៗទៅអត់រួចសុំគេឈប់មុនៗវីត្រែតជិតដល់អាយុវីត្រែតកអត់មានអីស៊ី ព្រោះយើងអត់បានទៅរៀនអីផងធ្វើការ បានតែប័ណ្ណសរសើរ ស៊ីអី ។

ធានី :	ចុះប្រាក់ខែអី?

នីម :	មាន ប៉ុនដល់យើងរីត្រែតយើងអត់មានធ្វើការបានច្រើនឆ្នាំ ធ្វើម៉េចបានស៊ីរីត្រែត បើបើចាប់ផ្ដើមរៀបចំរវល់ ។

ធានី :	ដល់យូរបានគេឲ្យ?

នីម :	ដឹងប៉ុន្មានខែប៉ុន្មានឆ្នាំអ្នកណាដឹង ដឹងគេឲ្យមិនឲ្យអ្នកណាដឹង ។

ធានី :	តាំងពីមីងធ្វើឆ្មបមក អ្នកដែលមីងជួយបង្កើតដែលគាត់មានយកនេះយកនោះអរគុណមីនទេ?

នីម :	មាន គ្មានអ្នកណាដែរអត់ ។

ធានី :	មកជួបលេងមីង?

នីម :	មក ខ្លះគេជូននំ ជូនទឹកក្រូច គេមកផ្ទះយាយៗដែលដៃទទេរ ។

ធានី :	មកលេងយាយ?

នីម :	ហ្នឹងហើយ លុយម៉ាម៉ឺន២ម៉ឺន នៅស្គាល់យាយដែរ ។

ធានី :	ចុះមីងដែលធ្លាប់បានជួយអ្នកជទៃនៅសម័យខ្មែរក្រហម?

នីម ៖ ជីមិនបានតាមផ្លូវ ជួយបង្កើតគេតាមផ្លូវ ។

ធានី ៖ ស្គាល់ឈ្មោះគាត់ទេ?

នីម ៖ ជួយបង្កើតប្រពន្ធតាផៃឈ្មោះ មិនា ។

ធានី ៖ ទៅបង្កើតនៅណា?

នីម ៖ បង្កើតនៅក្នុងព្រៃ ដឹងណា បើមិនដឹងលិចកើត ដឹងក្នុងព្រៃ កើតហើយអាឪបី អាម៉ែស្លាយ ដើរមកទៀត ខ្ញុំមកបាត់មកទៀត ខ្ញុំមកមុខទៀត ។ អ្នកណានៅនឹង គេទៅមុខអស់ហើយ ចេះតែទៅនឹង ។

ធានី ៖ នៅតែគាត់ប៉ុន្មាននាក់នឹងទេ?

នីម ៖ នៅប្ដីប្រពន្ធគាត់នឹងទៅ គ្នាគាត់មានប៉ុន្មាននាក់នៅនឹងចាំគ្នាទៅ ។

ធានី ៖ ហើយរាល់ថ្ងៃគាត់នៅណាវិញ?

នីម ៖ នៅខ្វាងរាប់ ។

ធានី ៖ ចង់សួរចិត្តមីង មីងយល់ថាការផ្សះផ្សា ការត្រូវរ៉ូវគ្នានឹង តើយើងគួរផ្សះផ្សានៅជិតឬនៅឆ្ងាយល្អជាង?

នីម ៖ ខ្ញុំនៅជិតគ្នាបានស្រួល ស្រណុកដឹងព្រឹកល្ងាច បើសិននៅឆ្ងាយគ្នាចេះរយាលទៅ គ្មានអ្នកណាឲ្យមតិទៅអ្នកណា គ្មានអ្នកណាជួយអ្នកណា ឆ្ងាយទៅៗ ។ ឥឡូវធៀបនឹងកូនមួយនៅថៃ កូនមួយនៅផ្ទះ ខ្ញុំយកអាជិតហើយ ខ្ជិលយកអាឆ្ងាយ ម៉ែឈឺវិញទ្រាំមកដល់ហើយ ។

ធានី ៖ មីងមាននៅសល់ឯកសារចាស់?

នីម ៖ អត់ ។ មានរូបថតជាមួយបារាំង រៀនជាមួយបារាំង(១៩៨០ជាង) ។

ធានី ៖ មីងមានអីចង់សួរខ្ញុំថែម?

នីម ៖ អត់ចង់សួរអី ។ សួរថាគេសម្ភាសន៍នឹងយកទៅធ្វើអី?

ធានី ៖ សម្ភាសន៍នឹងគ្រាន់តែយកទៅសរសេរជាសៀវភៅដូចខ្ញុំប្រាប់មីងបញ្ហាមីង ។

នីម ៖ អានឹង(បណ្ណសរសើរ)យកទៅសៀវភៅដែរ?

ធានី ៖ អត់ទេអានេះគ្រាន់ចង់បញ្ហាថាមីងមានផាររអីខ្វះនៅពេលឥឡូវ ចុះបើយើងមិននិយាយសម័យពី៧៩មកដល់ឥឡូវ ។ បើយើងអត់បញ្ហាថាយើងមានអីខ្វះ ធ្វើម៉េចយើងដឹងថាមីងរាល់ថ្ងៃធ្វើអី ។ ត្រូវទេមីង?

នីម ៖ ចា៎!

ធានី ៖ មានអីសង្ស័យទៀតអត់?

នីម ៖ អត់ទេ ។

ធានី ៖ អស់ហើយ អត់មានអីបន្ថែម?

នឹម ៖ ចា៎!

ធានី ៖ អរគុណច្រើនមីង ៗ

នឹម ៖ ចា៎! គ្មានអីថែមទៀតទេ ៗ

«ចប់»